# មាគ៌ាឆ្ពោះទៅរកយុត្តិធម៌

# សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្តោតលើ

# ជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច

## ជំពូកទី៤

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្រសួងយុត្តិធម៌ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៥

# ជំពូក IV
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជំពូកនេះជាសេចក្តីសន្និដ្ឋាន និងអនុសាសន៍យោងទៅលើការវិភាគទាំងឡាយដូចបានរៀបរាប់នៅក្នុងជំពូកមុនៗ។ ជំពូកទីមួយ បានរៀបរាប់ពីកម្មវត្ថុ វិធីសាស្ត្រស្រាវជ្រាវប្រភព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ។ ជំពូកទីពីរ បានវិភាគពីតម្រូវការយុត្តិធម៌នៅក្នុងសង្គម និងជំពូកទីបី បានធ្វើការសិក្សាពីការផ្តល់សេវាយុត្តិធម៌។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវបានរៀបចំឡើងដូចមានខាងក្រោម។ ដំបូងគឺទាក់ទងនឹងបញ្ហាចម្បង និងដំណោះស្រាយរយៈពេលវែង ដើម្បីរកដំណោះស្រាយចំពោះរាល់មូលហេតុនៃបញ្ហាទាំងនោះ ដែលជាទូទៅនៅក្រៅប្រព័ន្ធតុលាការ។ បន្ទាប់មកគឺការវាយតម្លៃលើស្ថាប័ន និងយន្តការដែលជាអ្នកផ្តល់សេវាយុត្តិធម៌នីមួយៗ។ ចុងក្រោយគឺការលើកជាអនុសាសន៍ជាក់លាក់មួយចំនួន ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។

## ម ា តិ ក ា


១. សេចក្តីសន្និដ្ឋាន....................២៥៥

១.១. បញ្ហា និងវិវាទចម្បងៗ និងដំណោះស្រាយរយៈពេលវែង....................២៥៥

១.១.១. វិវាទដែលមាននៅក្នុងសង្គម....................២៥៥

១.១.២. ការប្រើប្រាស់អំណាចហួសកម្រិត និងការរំលោភសិទ្ធិបុគ្គល....................២៥៦

១.១.៣. កង្វះខាតការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌....................២៥៧

១.១.៤. ជនជាតិដើមភាគតិច....................២៥៩

១.១.៥. គម្លាតរវាងតម្រូវការយុត្តិធម៌ជាសក្តានុពល និងតម្រូវការយុត្តិធម៌ជាក់ស្តែង....................២៦០

១.២. ការវាយតម្លៃលើការផ្តល់សេវាយុត្តិធម៌....................២៦២

២. អនុសាសន៍....................២៦៣

២.១. ពង្រឹង និងបង្កើតយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានា....................២៦៣

២.១.១. ពង្រឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានានៅនឹងថ្នាក់មូលដ្ឋាន....................២៦៣

២.១.២. បង្វិតអំណាចយុត្តាធិការឱ្យទៅជិតប្រជាពលរដ្ឋ: យុត្តិធម៌នៅមូលដ្ឋាន....................២៦៤

២.១.៣. ទទួលស្គាល់ និងពង្រឹងច្បាប់ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេ....................២៦៦

២.២. កែលំអយន្តការដោះស្រាយវិវាទក្រៅតុលាការ....................២៦៨

២.២.១. គណៈកម្មការសុរិយោដី....................២៦៨

២.២.២. ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ....................២៦៩

២.៣. កែលំអប្រព័ន្ធយុត្តិធម៌ផ្លូវការ..........២៦៩

២.៣.១. តុលាការ..........២៦៩

២.៣.២. នគរបាលយុត្តិធម៌..........២៧១

២.៣.៣. សេវាច្បាប់..........២៧១

២.៤. បង្កើនសមត្ថភាព និងផ្តល់អំណាចដល់ប្រជាពលរដ្ឋដើម្បីចូលរួមកែលំអសេវាកម្មយុត្តិធម៌..........២៧១

២.៥. បង្កើតឱ្យមានយន្តការដើម្បីសម្របសម្រួលក្នុងការផ្តល់សេវាយុត្តិធម៌..........២៧២

៣. តារាងសង្ខេប ស្តីអំពីកម្មវិធីទទួលបានយុត្តិធម៌ ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច..........២៧៤

៤. តារាងសង្ខេប ស្តីអំពីតម្រូវការ និងការផ្តល់សេវាយុត្តិធម៌សម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច..........២៨០

# ១. សេចក្តីសន្និដ្ឋាន

## ១.១. បញ្ហា និងវិវាទនានា និងដំណោះស្រាយរយៈពេលវែង

បញ្ហានិងវិវាទនានាដែលប្រឈមដោយអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច កើតចេញពីមូលហេតុខុសៗគ្នា។ បញ្ហា និងវិវាទទាំងនេះអាចចែកជាបួនក្រុមៈ ទីមួយសំដៅលើវិវាទនានាដែលកើតឡើងនៅតាមមូលដ្ឋានប្រចាំថ្ងៃ ទីពីរទាក់ទងនឹងភាពក្រីក្រ និងកង្វះការដាក់ឱ្យអនុវត្តសិទ្ធិខាងសង្គម សេដ្ឋកិច្ច និងវប្បធម៌ ទីបីទាក់ទងដល់ការរំលោភអំណាច និងការរំលោភសិទ្ធិបុគ្គល និងទីបួនសំដៅលើបញ្ហានានា ដែលជនជាតិដើមភាគតិចប្រឈមនៅក្នុងសហគមន៍របស់ពួកគេ។ វិវាទនានាដែលកើតមាននៅក្នុងសង្គម អាចត្រូវបែងចែកតាមបាតុភូតជាច្រើនដូចជាៈ (១). វិវាទនៅមូលដ្ឋានសំដៅលើវិវាទ ដែលកើតមាននៅក្នុងមូលដ្ឋាន ដោយសារទំនាក់ទំនងប្រចាំថ្ងៃរបស់ពលរដ្ឋ (២). អំពើហិង្សាខាងយេនឌ័រ (៣). វិវាទដីធ្លីធំៗ និងការបាត់បង់សិទ្ធិលើធនធានធម្មជាតិ រវាងភាគីមិនមានតុល្យភាពអំណាច ដោយភាគីម្ខាងជាអ្នកមានអំណាចជាង និង (៤). បទល្មើសព្រហ្មទណ្ឌ ។ មូលហេតុដែលបង្កឱ្យមានបញ្ហាទាំងនេះ ចាំបាច់ត្រូវតែយកចិត្តទុកដាក់ និងអនុម័តឱ្យមានដំណោះស្រាយរយៈពេលវែងនៅក្នុងបរិបទនៃសង្គម សេដ្ឋកិច្ច និងនយោបាយ ដើម្បីទប់ស្កាត់បញ្ហា និងវិវាទទាំងនេះកុំឱ្យកើតមាន។ ប្រព័ន្ធយុត្តិធម៌ផ្លូវការ (តុលាការ) មិនបានធ្វើការដោះស្រាយបញ្ហាសង្គម ដែលឋិតនៅពីក្រោយវិវាទទាំងនេះទេ។ សេវាយុត្តិធម៌ដោះស្រាយតែវិវាទដែលបានកើតឡើងរួចហើយប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក្តី បើសិនជាមានយន្តការគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហា និងវិវាទទាំងនេះ វានឹងអាចកាត់បន្ថយអំពើហិង្សាក្នុងសង្គម និងការរំលោភបំពានលើសិទ្ធិ។ ប្រជាជនត្រូវការយន្តការដែលមានយុត្តិធម៌ និងមានប្រសិទ្ធិភាពក្នុងការដោះស្រាយវិវាទ ការពារសិទ្ធិរបស់ពួកគេ និងត្រួតពិនិត្យការរំលោភអំណាច។

### ១.១.១. វិវាទដែលមាននៅក្នុងសង្គម

ក. វិវាទដែលមាននៅក្នុងមូលដ្ឋាន

**បញ្ហាៈ** វិវាទមួយចំនួនទាក់ទងនឹងរឿងតូចតាច ដែលកើតឡើងជារៀងរាល់ថ្ងៃ កើតឡើងពីអន្តរទំនាក់ទំនងក្នុងសង្គមនៅតាមតំបន់ជនបទ ដូចជារឿងវិវាទលើព្រំដី សត្វពាហនៈស៊ីដំណាំ ការប្រើប្រាស់អណ្តូង បំណុល វិវាទក្នុងគ្រួសារ ជម្លោះរវាងអ្នកជិតខាង ការបរិហារកេរ្តិ៍ និងបទល្មើសព្រហ្មទណ្ឌតូចតាច។ ម្តងម្កាលក៏មានកើតឡើងផងដែរនូវបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ តែមិនសូវញឹកញាប់ទេ និងបញ្ហាថ្មីៗ ដូចជាបញ្ហាក្រុមបងធំ។

**ដំណោះស្រាយៈ** វិវាទមួយចំនួនគឺជាផ្នែកមួយ នៃអន្តរទំនាក់ទំនងនៅក្នុងជីវិតសង្គមប្រចាំថ្ងៃ ដែលមិនអាចចៀសវាងបាន។ តែទោះជាយ៉ាងណាក្តី កង្វះការយកចិត្តទុកដាក់និងទប់ស្កាត់ទាន់ពេលវេលា នាំឱ្យបញ្ហាទាំងនោះកាន់តែធ្ងន់ធ្ងរ។ ហេតុនេះហើយវាគឺជារឿងសំខាន់ ដែលត្រូវមានយន្តការគ្រប់គ្រាន់នៅក្នុងសហគមន៍ ដើម្បីដោះស្រាយវិវាទនៅតាមមូលដ្ឋានមុនពេលវាកាន់តែរីកដុះដាលធំឡើងៗ ហើយវាក៏ចាំបាច់ត្រូវពង្រឹងវប្បធម៌សម្រាប់ការដោះស្រាយវិវាទ ដោយសន្តិវិធីផងដែរ។

ខ. **អំពើហិង្សាផ្នែកយេនឌ័រ**

បញ្ហាៈ ស្ត្រីជាញឹកញាប់ជួបប្រទះនឹងអំពើហិង្សាខាងយេនឌ័រ ដែលបង្កឡើងដោយបុរស ដូចជាអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ។ អំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រី និងកុមារជាបញ្ហាមួយដែលរីករាលដាលយ៉ាងខ្លាំងនៅទូទាំងប្រទេស។ អំពើហិង្សាក្នុងគ្រួសារនិងភាពមិនទទួលខុសត្រូវរបស់ឪពុក នាំមកនូវការផ្តាច់សង្វាស និងការលែងលះ។ ភាគច្រើនស្ត្រីជាអ្នកទទួលបន្ទុកលើការចំណាយសម្រាប់ការផ្តាច់សង្វាស និងការលែងលះ។ អំពើរំលោភសេពសន្ថវៈ និងការបំពារបំពានផ្លូវភេទទៅលើក្មេងស្រី និងស្ត្រីក៏ជារឿងមួយមានសភាពធ្ងន់ធ្ងរដែរ ដែលរឿងនេះច្រើនតែប្រព្រឹត្តដោយមនុស្សដែលស្គាល់គ្នាជាមួយជនរងគ្រោះ ដូចជា សាច់ញាតិ និងអ្នកជិតខាងជាដើម។

**ដំណោះស្រាយរយៈពេលវែង:** ដំណោះស្រាយសម្រាប់អំពើហិង្សាផ្នែកយេនឌ័រ មិនមែនអាចធ្វើទៅបានតាមប្រព័ន្ធយុត្តិធម៌តែឯងនោះទេ ប៉ុន្តែវាក៏ជាផ្នែកមួយនៃតួនាទីរបស់សង្គមផងដែរ។ វាជាការចាំបាច់ក្នុងការអនុវត្តគោលនយោបាយសង្គម សេដ្ឋកិច្ច និងវប្បធម៌រយៈពេលខ្លីនិងវែង ដើម្បីផ្ដល់អំណាចដល់ស្ត្រី (ការកែលំអលើការអប់រំ ប្រាក់ចំណូល។ល។) លើកកម្ពស់ ការយល់ដឹងពីសិទ្ធិ ពង្រឹងសិទ្ធិស្ត្រី និងកុមារ លើកតម្កើងទំនាក់ទំនងស្មើភាពខាងយេនឌ័រ បង្កើតវប្បធម៌ដោះស្រាយវិវាទដោយសន្តិវិធី ផ្ដល់ឱកាសឱ្យកាន់តែច្រើនឡើងសម្រាប់ការទទួលខុសត្រូវរបស់ឪពុកម្ដាយ។ ទោះជាយ៉ាងនេះក្ដី ប្រព័ន្ធយុត្តិធម៌ គឺជាផ្នែកមួយសំខាន់ក្នុងការកាត់បន្ថយអំពើហិង្សាខាងយេនឌ័រ តាមរយៈការពង្រឹងសិទ្ធិស្ត្រី និងកុមារ និងការកាត់បន្ថយបន្ទុកចំណាយសម្រាប់ស្ត្រីក្នុងការស្វែងរកយុត្តិធម៌ ក្នុងនាមជាជនរងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ និងក្នុងនាមជាដើមបណ្ដឹង នៃរឿងលែងលះ និងការសុំអាហារកិច្ច។

គ. បញ្ហាទាក់ទិននឹងវិវាទដីធ្លីធំៗ

**បញ្ហា:** វិវាទដីធ្លីធំៗរវាងអ្នកភូមិនិងភាគីមានអំណាច កើតឡើងដោយសារទីផ្សារទិញយកដី ដើម្បីកេងចំណេញដោយស្ថានភាពនៃការខ្វះការកំណត់ព្រំប្រទល់ដី និងការផ្ដល់ប័ណ្ណកម្មសិទ្ធិ (ដីធ្លីច្រើនជាង៨០%ជាដីដែលមិនទាន់ចុះបញ្ជី)។ អ្នកភូមិប្រឈមមុខនឹងការបាត់បង់ដីធ្លីរបស់គេ ឬសិទ្ធិប្រើប្រាស់ធនធានព្រៃឈើ ដោយសារតែសម្បទានដីធ្លី ដែលមិនមានតម្លាភាព ការចាប់យកដីធ្លី និងការវាតទីពង្រីកយកដីដោយខុសច្បាប់ ធ្វើឡើងដោយអ្នកមានអំណាច ក្រុមហ៊ុន យោធា និងមន្ត្រីឋានៈខ្ពស់មួយចំនួន។ ដីធ្លី និងធនធានធម្មជាតិ ភាគច្រើនមិនទាន់បានកំណត់ឱ្យបានត្រឹមត្រូវតាមច្បាប់នៅឡើយទេ ដោយសារតែភាពខ្វះខាតបទបញ្ញត្តិបន្ទាប់ច្បាប់ (អនុក្រឹត្យ) ខ្វះខាតការអនុវត្ត និងកង្វះតម្លាភាព។

**ដំណោះស្រាយរយៈពេលវែង:** ចំណាត់ថ្នាក់ប្រភេទដីធ្លី ការកំណត់ព្រំដី និងការផ្ដល់ប័ណ្ណកម្មសិទ្ធិ គឺជារឿងសំខាន់ក្នុងការចៀសវាងការធ្វើសម្បទានលើដីដែលកំពុងមានការកាន់កាប់ និងការទន្ទ្រានយកដីដោយខុសច្បាប់ពីសំណាក់អ្នកខាងក្រៅ និងការបណ្ដេញចេញដោយបង្ខំ។ វាមានភាពចាំបាច់ក្នុងការជម្រុញល្បឿននៃដំណើរការចុះបញ្ជីដីធ្លី ដែលកំពុងធ្វើនៅពេលបច្ចុប្បន្ន។ ឆន្ទៈនយោបាយ និងការត្រួតពិនិត្យពីសង្គមលើអំពើពុករលួយ គួរតែប្រព្រឹត្តទៅស្របគ្នាជាមួយដំណើរការនេះ។

ឃ. ករណីព្រហ្មទណ្ឌ (ឧក្រិដ្ឋភាព)

**បញ្ហា:** អំពើហិង្សា និងករណីព្រហ្មទណ្ឌជះឥទ្ធិពលអវិជ្ជមានដល់ប្រជាពលរដ្ឋ។ ក្នុងនោះករណីខ្លះ គឺជាបទល្មើសមានលក្ខណៈធ្ងន់ធ្ងរ និងមានបញ្ហាថ្មីៗជាច្រើន ដូចជាបញ្ហាទាក់ទងនឹងបងតូចបងធំជាដើម។

**ដំណោះស្រាយ:** ករណីព្រហ្មទណ្ឌ និងបញ្ហាបងតូចបងធំ មានការពាក់ព័ន្ធនឹងភាពក្រីក្រ និងកង្វះខាតឱកាសការងារ។ ដូចនេះ ដំណោះស្រាយជាចម្បងដើម្បីលុបបំបាត់នូវរាល់បញ្ហាព្រហ្មទណ្ឌប្រភេទទាំងនេះ គឺវាជាប់ទាក់ទិននឹងការផ្ដល់ឱកាសការងារសម្រាប់អ្នកក្រីក្រ និងជាពិសេសសម្រាប់យុវជន។ ចាំបាច់ត្រូវសិក្សាអំពីទំនាក់ទំនងរវាងអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាបងតូចបងធំ។ មានកុមារមួយចំនួនទទួលរងនូវហិង្សានៅក្នុងគ្រួសាររបស់គេ ហើយជាលទ្ធផលដល់ថ្ងៃក្រោយមក គេក៏បន្តប្រព្រឹត្តអំពើហិង្សានោះ តាមរូបភាពផ្សេងៗ ដូចជាចូលជាក្រុមបងតូចបងធំជាដើម ។

### ១.១.២. ការប្រើប្រាស់អំណាចហួសកម្រិត និងការរំលោភសិទ្ធិបុគ្គល

**បញ្ហា:** ការប្រើប្រាស់កម្លាំងសាធារណៈនៅក្នុងសង្គម ជាឧបករណ៍ដ៏មានអំណាចមួយ ដែលនាំឱ្យមានការរំលោភលើសេរីភាព និងសិទ្ធិបុគ្គល។ ក្នុងសង្គមប្រជាធិបតេយ្យ ដែលមានការបែងចែកអំណាច (ដូចដែលរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាបានចែង) រាល់ការប្រើប្រាស់កម្លាំង ត្រូវតែមានការត្រួតពិនិត្យក្នុងប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាច (check and balances)។ ការសិក្សាស្រាវជ្រាវនេះ បានរកឃើញនូវទម្រង់ផ្សេងៗនៃការរំលោភអំណាច ដែលនាំឱ្យមានការ

រំលោភសិទ្ធិបុគ្គល។ រូបភាពនៃការរំលោភអំណាចទាំងនោះអាចជា ៖

- រំលោភអំណាចដោយស្ថាប័ននីតិប្រតិបត្តិ (នគរបាល) នៅក្នុងបរិបទនៃការទប់ស្កាត់មិនឱ្យមានការតវ៉ានៅក្នុងសង្គម (ដូចជាតវ៉ាទាក់ទិននឹងវិវាទរឿងដីធ្លី និងវិវាទការងារជាដើម) ដែលជាលទ្ធផលអាចឈានដល់ការរំលោភសេរីភាពនិងសន្តិសុខបុគ្គល សេរីភាពក្នុងការជួបជុំប្រមូលផ្តុំ និងបូរណភាពខាងរូបកាយ។
- ការរំលោភលើវិធាននីតិវិធីច្បាប់ដោយនគរបាល មន្ត្រីយុត្តិធម៌ និងមន្ត្រីពន្ធនាគារដែលនាំឱ្យមាន៖ ការប្រព្រឹត្តមិនសមរម្យនៅពេលចាប់ខ្លួន ខ្វះអ្នកការពារក្តីនៅពេលសវនាការ ឃុំខ្លួនបណ្តោះអាសន្នហួសពេលកំណត់ និងស្ថានភាពពន្ធនាគារមិនសមរម្យ។ ការរំលោភទាំងនេះ អាចបណ្តាលមកពីកង្វះនូវសមត្ថភាព និងសំភារៈនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌពុំមានមេធាវីគ្រប់គ្រាន់ និងកង្វះគណនេយ្យភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ជាទូទៅ។
- ការរំលោភអំណាចក្នុងរូបភាពនៃអំពើពុករលួយ ក្នុងការផ្តល់សេវាយុត្តិធម៌ នាំឱ្យមានការរំលោភសិទ្ធិបុគ្គល និងភាពលម្អៀង។ តាមរយៈសិក្ខាសាលា អ្នកចូលរួមក្នុងសិក្ខាសាលាទាំងឡាយបានត្អូញត្អែរអំពីការបង់ប្រាក់ខុសច្បាប់ ដែលទាមទារដោយនគរបាលនិងមន្ត្រីតុលាការ ព្រមទាំងត្អូញត្អែរផងដែរអំពីភាពលម្អៀងក្នុងការផ្តល់សេវាយុត្តិធម៌។ អំពើពុករលួយប៉ះពាល់ដល់ទស្សនាទានស្តីអំពីយុត្តិធម៌ ដោយរាល់ដំណោះស្រាយគឺពឹងផ្អែកសំខាន់លើទ្រព្យសម្បត្តិ ការប្រើប្រាស់លុយកាក់ និងអំណាចរបស់គូភាគីនៃវិវាទ។

**ដំណោះស្រាយរយៈពេលវែង៖** ការរំលោភអំណាច មានការទាក់ទងនឹងភាពខ្វះខាតប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាច (check and balance) របស់ស្ថាប័ន ក៏ដូចជាភាពខ្វះខាតនៃការត្រួតពិនិត្យរបស់សង្គម។ ហេតុនេះវាគឺជាការចាំបាច់ក្នុងការពង្រឹងការយល់ដឹងអំពីសិទ្ធិ និងលើកកំពស់គណនេយ្យភាពសង្គម។ នៅក្នុងរឿងព្រហ្មទណ្ឌ ចាំបាច់ត្រូវមានការអនុវត្តប្រព័ន្ធដោយឡែកសម្រាប់ជនល្មើសអនីតិជន។ ក្រមព្រហ្មទណ្ឌគួរតែបញ្ចូលផងដែរ នូវឱកាសដោះស្រាយដោយការចរចាររបស់ភាគី (plea-bargainning) វិធានការជំនួសពន្ធនាគារ និងការបន្ធូរបន្ថយរយៈពេលដាក់ក្នុងពន្ធនាគារសម្រាប់អ្នកដែលខំធ្វើការ និងខំសិក្សានៅពេលជាប់ពន្ធនាគារ។ ប្រព័ន្ធយុត្តិធម៌នៅក្នុងករណីព្រហ្មទណ្ឌ គួរតែផ្តោតសំខាន់លើបទល្មើសធ្ងន់ធ្ងរ ហើយអនុញ្ញាតឱ្យបទល្មើសតូចតាច អាចត្រូវបានដោះស្រាយតាមវិធីផ្សេងៗទៀត។ នេះជាការចាំបាច់ណាស់ក្នុងការអនុវត្តនូវយន្តការមួយ ដែលប្រកបដោយគណនេយ្យភាពចំពោះស្ថាប័ន និងសង្គមដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម ដោយនគរបាលក្រោយការចាប់ខ្លួន និងការប្រព្រឹត្តអមនុស្សធម៌នៅក្នុងមន្ទីរឃុំឃាំង។

### ១.១.៣. កង្វះខាតការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌

**បញ្ហា៖** កង្វះខាតនូវលក្ខខណ្ឌរស់នៅសមរម្យសម្រាប់ជនក្រីក្រ ដែលជារនាំងក្នុងការទទួលបានសមរម្យនូវសេចក្តីត្រូវការមូលដ្ឋាន ដូចជាអាហារ ការអប់រំ សុខភាព និងលំនៅដ្ឋាន គឺជាមូលហេតុមួយដែលនាំឱ្យមានបញ្ហា និងវិវាទនានា។ បញ្ហាទាំងនេះ ជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌរយៈពេលវែង ព្រមទាំងរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមផងដែរ។ រដ្ឋធម្មនុញ្ញក៏ដូចជាឧបករណ៍អន្តរជាតិផ្សេងៗទៀតស្តីពីសិទ្ធិមនុស្ស បានផ្តល់និងធានានូវសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសសម្រាប់ជនក្រីក្រ ស្ត្រីដែលជាម្តាយ និងកុមារទាំងឡាយដែលជួបប្រទះនូវសេចក្តីត្រូវការទាំងនេះ។ ទោះជាយ៉ាងនេះក្តី តាមបទបញ្ញត្តិទាំងឡាយដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិនានាតម្រូវឱ្យមានការអនុវត្តជាបណ្តើរៗ ក្នុងរយៈពេលវែង។ ប្រជាពលរដ្ឋក្រីក្រខ្វះការយល់ដឹងអំពីសិទ្ធិសង្គម វប្បធម៌ និងសេដ្ឋកិច្ចរបស់ខ្លួន។ ទោះបីជាមានស្ថាប័នសម្រាប់ផ្តល់សេវាសុខភាព និងសេវាអប់រំសម្រាប់ជនក្រីក្រ និងកុមាររួចហើយក៏ដោយក្តី តែជាក់ស្តែងការទទួលយកសេវាទាំងនេះ និងការអនុវត្តនៅមានកម្រិតនៅឡើយ ដោយសារតែអំពើពុករលួយក្នុងការផ្តល់សេវាកម្មទាំងនោះ។

យោងតាមអ្នកដែលចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលក្រុមការងារបានសម្ភាស បានលើកឡើងថាមានអំពើពុករលួយក្នុងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងទ្រព្យធនធានសាធារណៈ។ កត្តានេះនាំឱ្យមានការរំលោភលើសិទ្ធិសង្គម និងប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ អំពើពុករលួយតាមរូបភាពនេះ គឺបណ្តាលមកពីខ្វះអភិបាលកិច្ចល្អ។ ប្រជាពលរដ្ឋយល់ថា អំពើពុករលួយមានលក្ខណៈទូទៅ និងទូលំទូលាយ។ ទោះបីជាមានទស្សនៈទូទៅអំពីអំពើពុករលួយក៏ដោយក្តី តែមានពាក្យបណ្តឹងផ្លូវការតិចតួចណាស់ ដែលពាក់ព័ន្ធនឹងរឿងក្តីអំពើពុករលួយ។ ប្រជាពលរដ្ឋដែលរងគ្រោះដោយអំពើពុករលួយយល់ឃើញថាតុលាការមិនអាចត្រួតពិនិត្យអំពើពុករលួយបានឡើយ។ លើសពីនេះទៅទៀត ជាញឹកញាប់ប្រជាពលរដ្ឋមិនបានយល់អំពីសិទ្ធិសង្គមរបស់ពួកគេទេ ដូចនេះហើយពួកគេមិនប្តឹងតាមផ្លូវច្បាប់ ដើម្បីទាមទារសិទ្ធិទាំងនោះឡើយ។ បើសិនជាមានពាក្យបណ្តឹងពីអំពើពុករលួយនោះ ករណីនេះនឹងត្រូវបានគេចាត់ការតាមបែបជាករណីរដ្ឋបាល ឬនយោបាយទៅវិញ។ ទោះជាអំពើពុករលួយត្រូវបានគេមើលឃើញថា ជាបញ្ហាធំធេងទូទៅ និងរីករាលដាលក៏ដោយតែតាមស្ថិតិរឿងក្តីនៅតុលាការដែលបានសម្រេចហើយក្នុងឆ្នាំ ២០០៣ និង ២០០៤ ពុំមានករណីណាមួយទាក់ទិនរឿងពុករលួយឡើយ។ រូបភាពនៃអំពើពុករលួយដែលជះឥទ្ធិពលដល់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិចខ្លាំងជាងគេមានដូចជា ៖

- កង្វះនូវតម្លាភាព និងអំពើពុករលួយនៅក្នុងការគ្រប់គ្រងធនធានឬសម្បត្តិសាធារណៈ ដូចជាការធ្វើសម្បទានដីធ្លី និងសម្បទានធនធានធម្មជាតិ ការអនុញ្ញាតឱ្យមានការទន្ទ្រានយកដីធ្លី ភាពមិនប្រក្រតីខាងលទ្ធកម្ម ការអនុញ្ញាតសិទ្ធិធ្វើអាជីវកម្ម ការរៀបចំសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសេចក្តីសម្រេចខាងនយោបាយដទៃៗទៀតទៅលើសម្បត្តិសាធារណៈ សេវាកម្ម និងពន្ធដារ។ កត្តាទាំងនេះអាចជះឥទ្ធិពលដោយផ្ទាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្រីក្រ ដោយសារថាពួកគេជាអ្នករងគ្រោះ ដោយការបាត់បង់សិទ្ធិលើដីធ្លី និងបង្កឱ្យមានភាពក្រីក្រ។ ជនរងគ្រោះដោយសារកត្តាទាំងនេះយល់ឃើញថា នេះជាស្ថានភាពមួយដែលបង្កឱ្យមានភាពអយុត្តិធម៌។ ពេលខ្លះអ្នករងគ្រោះទាំងនោះ ព្យាយាមធ្វើការតវ៉ាសង្គមតាមរយៈខ្សែបណ្តាញបក្សនយោបាយដើម្បីដោះស្រាយបញ្ហា។ អំពើពុករលួយបែបនេះ មានការប៉ះពាល់ដ៏សំខាន់ដល់សេដ្ឋកិច្ចជាតិ។ វាស្រូបយកធនធានហិរញ្ញវត្ថុពីជាតិ(រដ្ឋ) ដែលធនធានហិរញ្ញវត្ថុទាំងនេះអាចត្រូវបានគេប្រើសម្រាប់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដូចជាវិស័យអប់រំ សុខាភិបាល និងយុត្តិធម៌ជាដើម។
- អំពើពុករលួយក្នុងការផ្តល់សេវាសាធារណៈ ដូចជាក្នុងវិស័យអប់រំ និងសុខាភិបាលជាដើម។ អំពើពុករលួយនេះនាំឱ្យមានការរំលោភសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌ ដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ។ ប្រាក់ខែទាបជាមូលហេតុមួយ ដែលនាំឱ្យមានការតម្រូវឱ្យបង់ប្រាក់ដោយខុសច្បាប់ ពីគ្រូបង្រៀន ពេទ្យ និងមន្ត្រីសាធារណៈជាផ្នូរនឹងការផ្តល់សេវាសាធារណៈ។ ពេលខ្លះការដែលតម្រូវឱ្យបង់ប្រាក់ដោយខុសច្បាប់បែបនេះ នាំឱ្យក្មេងៗមិនអាចចូលសាលាបាន អ្នកក្រីក្រមិនអាចទទួលបានសេវាសុខភាពបាន ហើយជនរងគ្រោះនៃបទល្មើសផ្សេងៗ មិនអាចទទួលនូវការធ្វើកោសល្យវិច្ច័យបានទេ។ មនុស្ស ជាច្រើនមិនបានចាត់ទុកថាអំពើពុករលួយនេះ ជាការរំលោភលើសិទ្ធិសង្គម ហើយពួកគេក៏មិនដឹងថាពួកគេអាចប្តឹងដើម្បីទាមទារសិទ្ធិទាំងនេះតាមផ្លូវច្បាប់ឡើយ។
- អំពើពុករលួយក្នុងរដ្ឋបាលសាធារណៈ។ អំពើពុករលួយបែបនេះគឺជាការរំលោភអំណាចដ៏ខ្លាំងក្លាមួយ ដែលអាចរកឃើញនៅតាមៈ ការិយាល័យចុះបញ្ជីការ (ទ្រព្យសម្បត្តិ និងអគ្រានុកូលដ្ឋានជាដើម) ការបញ្ជាក់ឯកសារសំគាល់ខ្លួន ការផ្តល់សេវាសាធារណៈដូចជាសេវាប្រៃសណីយ៍ ការបង្វិលថវិកាពីរតនាគារទៅឱ្យក្រុមប្រឹក្សាឃុំ និងបញ្ហាដទៃៗទៀត។ អំពើពុករលួយនេះមួយផ្នែកជាប់ទាក់ទងទៅនឹងប្រព័ន្ធរដ្ឋបាលបរិបាលកិច្ចទៅក្នុងស្ថាប័នរដ្ឋ (ដូចជាមុខតំណែងសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវបានគេចាត់ទុកថាជាកេរ្តិ៍របស់មន្ត្រីសាធារណៈទាំងនោះ ដែលពួកគេអាចលក់ និងទិញមុខតំណែងនិងសម្បត្តិទាំងនោះ

បាន។ យោងតាមព័ត៌មានទទួលបានពីអ្នកដែលត្រូវបានសម្ភាស បានឱ្យដឹងថាតំណែងជាច្រើនត្រូវបានទទួលតាមរយៈអ្នកមានឥទ្ធិពល ឬតាមការបង់ប្រាក់ ដោយគ្មានការត្រួតពិនិត្យច្បាស់លាស់ជាសាធារណៈ ឬនីតិវិធីជ្រើសរើសគ្មានតម្លាភាព។ ជាលទ្ធផលនាំឱ្យមន្ត្រីរាជការ ជាញឹកញាប់យល់ថាមុខងារក្នុងការផ្តល់សេវាសាធារណៈ ជាប្រភពដើម្បីរកចំណូលលើសពីប្រាក់ខែដែលខ្លួនត្រូវទទួល។ ជាទូទៅប្រាក់ខែរបស់មន្ត្រីរាជការមានកម្រិតទាប ដែលមិនអាចឱ្យពួកគាត់ ផ្គត់ផ្គង់ចំណាយទ្រទ្រង់ជីវិតប្រចាំថ្ងៃបានឡើយ។

**ដំណោះស្រាយរយៈពេលវែង:** ការដែលប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ និងខ្វះការយល់ដឹងអំពីសិទ្ធិមនុស្ស មិនមែនមានន័យថា ប្រជាពលរដ្ឋទាំងនោះពុំដឹងអំពី *តម្រូវការសង្គម* ទាំងឡាយរបស់ពួកគេឡើយ។ មនុស្សគ្រប់រូបដឹងអំពី *តម្រូវការ*របស់ខ្លួន ហើយព្យាយាមរុករកគ្រប់វិធី ដើម្បីទទួលបាននូវអ្វីដែលខ្លួន*ត្រូវការ*នេះ បើទោះបីជាពួកគាត់មិនបានហៅ*តម្រូវការនេះ*ថាជា "***សិទ្ធិ***" ឬមិនបានប្តឹងតាមផ្លូវច្បាប់ ដើម្បីទាមទារនូវ*តម្រូវការ*ទាំងនោះក៏ដោយ។ បើសិនជានៅក្នុងសង្គមមួយ មិនបានផ្តល់នូវយន្តការមួយប្រកបដោយសន្តិភាព ប្រជាធិបតេយ្យ និងប្រសិទ្ធិភាពដើម្បីដោះស្រាយ និងឆ្លើយតបចំពោះតម្រូវការរបស់សង្គមនេះនោះ ប្រជាពលរដ្ឋអាចនាំគ្នាប្រព្រឹត្តអំពើហិង្សា រួមទាំងការធ្វើកុប្បកម្មដើម្បីទាមទាររកយុត្តិធម៌។ សិទ្ធិទទួលបានយុត្តិធម៌នឹងមានប្រសិទ្ធិភាព ហើយអភិបាលកិច្ចល្អនឹងកើតមានលុះណាតែ *តម្រូវការសង្គម*ត្រូវបានគេផ្តល់ឱ្យយ៉ាងពេញលេញ។ គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងប្រជាធិបតេយ្យភាវូបនីយកម្ម ចាំបាច់ត្រូវតែមានដើម្បីដោះស្រាយបញ្ហានេះ។ ការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់ពួកគេ ត្រូវតែដើរទន្ទឹមគ្នាជាមួយការបង្កើតឱ្យមានយន្តការ សម្រាប់ការចូលរួមប្រកបដោយប្រជាធិបតេយ្យនៅក្នុងជីវិតសង្គម សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេស។

### ១.១.៤. ជនជាតិដើមភាគតិច

***ភាពក្រីក្រ និងកង្វះខាតនៃការផ្តល់សេវាសាធារណៈ:*** ជាទូទៅជនជាតិដើមភាគតិចទទួលបានសេវាសាធារណៈតិចតួច ដូចជាការអប់រំនិងសុខភាពជាដើម។ សេវាទាំងនោះមិនត្រូវបានផ្តល់ដោយគិតដល់ភាសា និងវប្បធម៌របស់ពួកគេទេ។ ជនជាតិដើមភាគតិច មិនមានតំណាងសមស្របនៅក្នុងរចនាសម្ព័ន្ធអំណាច នៃរដ្ឋបាលថ្នាក់ខេត្តទេ។ ដូចនេះសម្រាប់ជនជាតិដើមភាគតិច វាជាការចាំបាច់ដែលរដ្ឋាភិបាល ត្រូវបង្កើតគោលនយោបាយជាក់លាក់ សម្រាប់ការចូលរួមរបស់ពួកគេ ដើម្បីពង្រឹងសិទ្ធិរបស់ខ្លួន ធានាដល់ដីធ្លី និងចីរភាពនៃសេដ្ឋកិច្ចរបស់ពួកគេ ព្រមទាំងលើកកំពស់សមត្ថភាពរបស់គេក្នុងការចូលរួមពង្រឹងអត្តសញ្ញាណវប្បធម៌និងតម្លៃរបស់ខ្លួន និងប្រើប្រាស់សេវាសាធារណៈបានគ្រប់គ្រាន់ ស្របតាមភាសា និងវប្បធម៌របស់ពួកគេ។

***វិវាទនៅក្នុងសហគមន៍:*** ជនជាតិដើមភាគតិចក៏ប្រឈមមុខផងដែរនឹងវិវាទផ្សេងៗ នៅក្នុងមូលដ្ឋានដែលកើតចេញពីអន្តរទំនាក់ទំនងក្នុងសង្គមប្រចាំថ្ងៃរបស់ពួកគេ ដូចជាកសិកម្មពនេចរ រឿងរ៉ាវក្នុងគ្រួសារ ជម្លោះរវាងអ្នកជិតខាង ការចោទប្រកាន់លើអំពើអាបធ្មប់។ល។ ពួកគេក៏ប្រឈមមុខផងដែរនឹងបញ្ហាថ្មីៗ ទាក់ទងនឹងការផ្លាស់ប្តូររបស់សង្គម វត្តមាននៃអ្នកចំណូលថ្មី បញ្ហាក្រុមបងធំ។ល។ សហគមន៍ជនជាតិដើមភាគតិចមានអាជ្ញាធរ វិធានទំនៀមទម្លាប់ និងយន្តការដោះស្រាយវិវាទរបស់ពួកគេខ្លួនឯង។ យន្តការទាំងនោះឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងសង្គម និងប្រពៃណីវប្បធម៌របស់ពួកគេ ដែលត្រូវបានពួកគេទទួលស្គាល់ និងបានផ្តល់យុត្តិធម៌ជាភាសារបស់ខ្លួនតែម្តង។ យន្តការទាំងនោះ ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់របស់ពួកគេផ្ទាល់ គួរតែត្រូវបានគេគោរពនិងពង្រឹងឡើង។ ច្បាប់ភូមិបាលបានទទួលស្គាល់ វិធានទំនៀមទម្លាប់ អាជ្ញាធរ និងដំណើរការធ្វើសេចក្តីសម្រេច របស់ជនជាតិដើមភាគតិចមួយកម្រិតរួចហើយ។ ហេតុនេះវាជាការចាំបាច់ក្នុងការធ្វើការផ្សព្វផ្សាយនិងអនុវត្តច្បាប់នោះ។ វាជារឿងចាំបាច់ដែលត្រូវបំពេញការយល់ដឹង និងចែងឱ្យបានច្បាស់រវាងយន្តការយុត្តិធម៌របស់ជនជាតិដើមភាគតិច និងប្រព័ន្ធយុត្តិធម៌ជាតិ។

**អំពើហិង្សាខាងយេនឌ័រៈ** ដោយសារតែសហគមន៍ជនជាតិដើមភាគតិច មានទំនាក់ទំនងសង្គមខ្លាំងក្លា វាហាក់ដូចជាមានការគ្រប់គ្រងរបស់សង្គមច្រើន ទៅលើអំពើហិង្សាក្នុងគ្រួសារ និងកាតព្វកិច្ចរបស់ឪពុកម្តាយ ហើយជាលទ្ធផលគេឃើញមានអំពើហិង្សាក្នុងគ្រួសារ កើតឡើងតិចជាងនៅក្នុងចំណោមគ្រួសារជនជាតិខ្មែរ។ តែទោះជាយ៉ាងនេះក្តី ស្ថានភាពសង្គមថ្មីៗបានបង្កើតជាឥទ្ធិពលអវិជ្ជមាន។ នៅក្នុងទីផ្សារសេដ្ឋកិច្ច បុរសច្រើនដើរតួនាទីសំខាន់ជាងស្ត្រី ក្នុងការធ្វើអន្តរទំនាក់ទំនងជាមួយអ្នកខាងក្រៅ ដែលធ្វើឱ្យស្ត្រីមានអំណាចសម្រេចតិចជាងលើរឿងសេដ្ឋកិច្ចគ្រួសារ។ ជម្លោះដែលកើតឡើងពីការទទួលទានស្រា ក៏កើតមានឡើងជារឿយៗផងដែរ។ វាជាការសំខាន់ដែលត្រូវផ្តល់អំណាចឱ្យស្ត្រី ឱ្យស្របតាមការផ្លាស់ប្តូរទាំងនេះ ដោយលើកតម្កើងការយល់ដឹងពីសិទ្ធិស្ត្រី និងផ្តល់ឱ្យពួកគេនូវឱកាសថ្មីៗសម្រាប់ការអប់រំដល់ពួកគេ (ដើម្បីកាត់បន្ថយភាពមិនចេះអក្សររបស់ស្ត្រី) និងការអភិវឌ្ឍ។

**ការទន្ទ្រានយកដីធ្លីដោយអ្នកខាងក្រៅៈ** ការទន្ទ្រានយកដីធ្លីសហគមន៍ដោយអ្នកខាងក្រៅ គឺជាបញ្ហាធ្ងន់ធ្ងរបំផុតដែលជនជាតិដើមភាគតិចជួបប្រទះ ហើយភាពខ្វះខាតដីសហគមន៍របស់ពួកគេ អាចគំរាមកំហែងដល់អត្ថិភាពរបស់ពួកគេក្នុងនាមជាប្រជាជន។ ដំណើរបាត់បង់ដីធ្លីសហគមន៍ បានកើតឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែការរីករាលដាលនៃបណ្តាញអ្នកស៊ីកំរៃជើងសារ ដោយមានការចូលរួម ឬដោយមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន។ អ្នកស៊ីកំរៃជើងសារ បានទាញយកប្រយោជន៍លើហេតុផលជាតិពន្ធុ មកគំរាមកំហែងដល់សហគមន៍ជនជាតិដើមភាគតិច និងប្រើល្បិចឱ្យអ្នកទាំងនោះលក់ដីធ្លីរបស់ខ្លួន។ ការខ្វះខាតការកំណត់ព្រំប្រទល់ដីរបស់សហគមន៍ ការរំលោភអំណាច និងកង្វះភាពយល់ដឹងពីសិទ្ធិរបស់ជនជាតិដើមភាគតិច បានក្លាយជាបញ្ហាស្នូល ដែលនាំឱ្យមានការទន្ទ្រានយកដីធ្លីដោយខុសច្បាប់ ដោយអ្នកខាងក្រៅ។ ដើម្បីទប់ស្កាត់នូវរាល់ប្រភពបញ្ហាទាំងនេះ ចាំបាច់ត្រូវជម្រុញការកំណត់ព្រំប្រទល់ដីធ្លី ផ្សព្វផ្សាយច្បាប់ភូមិបាល លើកតម្កើងការយល់ដឹងសិទ្ធិរបស់ជនជាតិដើមភាគតិច ត្រួតពិនិត្យការអនុវត្តខុសច្បាប់ លើកកំពស់ឱ្យមានការត្រួតពិនិត្យសង្គមលើអំពើពុករលួយ និងឱកាសអភិវឌ្ឍន៍សេដ្ឋកិច្ច សម្រាប់សហគមន៍ជនជាតិដើមភាគតិច។

**សិទ្ធិបុគ្គលៈ** ស្ថានភាពរបស់ជនជាតិដើមភាគតិច ដែលប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ជួបប្រទះនឹងការលំបាកច្រើនជាងជនជាតិខ្មែរ ដោយសារគ្មានអ្នកបកប្រែ និងពុំមានមេធាវីការពារក្នុងពេលបើកសវនាការ។ តុលាការនៅឆ្ងាយពីសហគមន៍របស់គេ ហើយពួកគេមិនបានដឹងពីប្រព័ន្ធច្បាប់នោះទេ។ វាជាការសំខាន់ក្នុងការពង្រឹងច្បាប់ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ដើម្បីឱ្យគេអាចដោះស្រាយជាមួយជនល្មើស ដែលជាជនជាតិដើមភាគតិចបាន។ វាក៏មានភាពចាំបាច់ផងដែរ ក្នុងការផ្តល់មេធាវី និងអ្នកបកប្រែសម្រាប់ជនជាតិដើមភាគតិច នៅក្នុងដំណើរការក្តីផ្លូវច្បាប់ និងសេវាសាធារណៈ។

### ១.១.៥. គម្លាតរវាងតម្រូវការយុត្តិធម៌ជាសក្តានុពល និងតម្រូវការយុត្តិធម៌ជាក់ស្តែង

បញ្ហាៈ មានវិវាទ និងស្ថានភាពរំលោភសិទ្ធិដែលនៅតែត្រូវបានគេយល់ថាជាបញ្ហាសង្គម និងមិនអាចចាត់ទុកថាជារឿងក្តីបាន ដោយសារតែខ្វះភាពយល់ដឹងពីសិទ្ធិនិងច្បាប់។ បញ្ហាដែលប្រជាពលរដ្ឋជួបប្រទះទាំងនេះ ជាឧទាហរណ៍ដែលបង្ហាញពីភាពអយុត្តិធម៌ ដែលផ្ទុយនឹងសេចក្តីត្រូវការ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ប៉ុន្តែពួកគេមិនបានដឹងថាពួកគេមានសិទ្ធិប្តឹងតទល់នឹងការរំលោភទាំងនោះ ដើម្បីរកដំណោះស្រាយឡើយ។ ក្នុងស្ថានភាពខ្លះ តាមពិតទៅការរំលោភទាំងនេះមានចរិតជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែវាមិនត្រូវបានគេយកមកដោះស្រាយ ជាប្រភេទបទល្មើសព្រហ្មទណ្ឌទេ (Black cipher of criminality) ដោយសារតែគ្មានអ្នកប្តឹងអំពីបញ្ហាទាំងនោះ។ ករណីមួយចំនួនទៀត ប្រជាពលរដ្ឋយល់និងដឹងថា សិទ្ធិរបស់ខ្លួនត្រូវបានគេរំលោភ ឬខ្លួនរងគ្រោះដោយបទព្រហ្មទណ្ឌ តែមិនមានយន្តការណាមួយដែលគេអាចប្តឹងដើម្បីទាមទាររកយុត្តិធម៌ឡើយ។ បញ្ហាទាំងនេះមានដូចរៀបរាប់ខាងក្រោមនេះ :

- អំពើរំលោភលើសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌
- អំពើពុករលួយ
- ការធ្វើទារុណកម្ម និងការរំលោភសិទ្ធិមនុស្ស
- ការរំលោភលើសិទ្ធិរបស់អ្នកជាប់ពន្ធនាគារ
- អំពើហិង្សាខាងយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងរំលោភសេពសន្ថវៈ
- ការទន្ទ្រានយកដីសហគមន៍របស់ជនជាតិដើមភាគតិចដោយអ្នកខាងក្រៅ

| ពង្រីកការយុត្តិធម៌ជាសក្តានុពល | | ពង្រីកការយុត្តិធម៌ជាក់ស្តែង |
|---|---|---|
| បញ្ហាសង្គម និងវិវាទចម្បងៗ | បញ្ហា និងវិវាទដែលគេយល់ថាជា *រឿងក្តី (អាចប្តឹងរកយុត្តិធម៌បាន)* | រឿងក្តីដែលត្រូវបានដាក់ពាក្យបណ្តឹង រួចហើយទៅកាន់ភ្នាក់ងារណាមួយ |
| - ភាពក្រីក្រ<br>- វិវាទដីធ្លី<br>- អំពើហិង្សាក្នុងគ្រួសារ និងការបោះបង់ចោលគ្រួសារ<br>- សុខភាពសាធារណៈ<br>- បំណុល<br>- ការរំលោភសិទ្ធិមនុស្ស<br>- បទល្មើសព្រហ្មទណ្ឌ<br>- អំពើពុករលួយ<br>- លំនៅដ្ឋាន | - វិវាទដីធ្លី<br>- អំពើហិង្សាក្នុងគ្រួសារ<br>- ការលែងលះ និងអាហារកិច្ច<br>- អំពើរំលោភសេពសន្ថវៈ<br>- វិវាទនៅក្នុងមូលដ្ឋាន<br>- ការបរិហាកេរ្តិ៍<br>- បទល្មើសដទៃទៀត<br>- បំណុល<br>- ការរំលោភសិទ្ធិមនុស្ស<br>- អំពើពុករលួយ<br>- រឿងក្តីរដ្ឋប្បវេណីផ្សេងៗ | - វិវាទដីធ្លី<br>- អំពើហិង្សាក្នុងគ្រួសារ<br>- អំពើរំលោភសេពសន្ថវៈ<br>- វិវាទនៅក្នុងមូលដ្ឋាន<br>- ការបរិហាកេរ្តិ៍<br>- បទល្មើសព្រហ្មទណ្ឌ<br>- បំណុល និងការរំលោភលើកិច្ចសន្យា<br>- រឿងក្តីរដ្ឋប្បវេណីផ្សេងៗទៀត |

វិធានការចាំបាច់ដែលត្រូវ:

ក- ពង្រឹងគោលនយោបាយសម្រាប់ការផ្សព្វផ្សាយច្បាប់ និងការយល់ដឹងពីសិទ្ធិ ក្នុងចំណោមមន្ត្រីតុលាការ ក៏ដូចជា អ្នកប្រើប្រាស់អំពី:

- សិទ្ធិសង្គម សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងសិទ្ធិបុគ្គល
- សិទ្ធិរបស់ស្ត្រី និងកុមារ
- សិទ្ធិរបស់ជនជាតិដើមភាគតិច ។

ខ- ផ្តល់មេធាវី និងអ្នកបកប្រែភាសាសម្រាប់ជនជាតិដើមភាគតិច ។

គ- សម្របសម្រួលការទទួលបានសេវាយុត្តិធម៌សម្រាប់មនុស្សទាំងអស់គ្នា ។

## ១.២. ការវាយតម្លៃលើការផ្តល់សេវាយុត្តិធម៌

សេវាយុត្តិធម៌ត្រូវបានផ្តល់ដោយយន្តការ ស្ថាប័ន និងអង្គភាពខុសៗពីគ្នា ដោយមានឬគ្មានសមត្ថភាពផ្លូវច្បាប់ក្នុងការផ្តល់សេវាយុត្តិធម៌។ ប្រជាពលរដ្ឋចូលចិត្តយន្តការមួយចំនួនជាងយន្តការដទៃទៀត ដោយសារតែភាពងាយស្រួលខាងភូមិសាស្ត្រឬសេដ្ឋកិច្ច ការយល់ដឹងពីវប្បធម៌និងមូលហេតុនៃទំនាស់ ឬសមត្ថភាពក្នុងការដោះស្រាយរឿងវិវាទ។ ក្នុងចំណោមយន្តការផ្សេងៗ ស្ថាប័ន និងយន្តការដែលប្រជាពលរដ្ឋចូលចិត្ត រួមមាន :

- អាជ្ញាធរមូលដ្ឋាន ដូចជាមេភូមិ និងក្រុមប្រឹក្សាឃុំ ដែលមានទីតាំងនៅថ្នាក់ភូមិ និងថ្នាក់ឃុំ
- អាជ្ញាធរជនជាតិដើមភាគតិច ដែលឋិតនៅក្នុងសហគមន៍ជនជាតិដើមភាគតិចស្រាប់
- នគរបាល ដែលមាននៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ
- អាជ្ញាធររដ្ឋាភិបាល ដូចជាអភិបាលស្រុក និងអភិបាលខេត្ត នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត
- គណៈកម្មការសុរិយោដី ដែលមាននៅថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ ដែលមានទីតាំងនៅភ្នំពេញ
- ប្រព័ន្ធតុលាការ ( អយ្យការ និងតុលាការ) ដែលមានទីតាំងនៅថ្នាក់ខេត្ត-ក្រុង និងថ្នាក់ជាតិ

ចេញពីការសិក្សាស្រាវជ្រាវនេះ នាំឱ្យមានការសន្និដ្ឋានមួយចំនួនដូចជាៈ ក-ប្រជាជនភាគច្រើនមិនអាចទៅរកដំណោះស្រាយតាមផ្លូវតុលាការទេ ជាពិសេសអ្នកក្រីក្រ និងជនដែលបាត់បង់អត្ថប្រយោជន៍ ហើយ ខ-វិធានការមួយក្នុងការលើកកំពស់ការទទួលបានយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ ដែលរស់នៅក្នុងឃុំតាមតំបន់ជនបទ គឺត្រូវទទួលស្គាល់ ឬបង្កើតស្ថាប័ននៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមវិធីណាក៏ដោយ ដើម្បីដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន ជាពិសេសសម្រាប់រឿងក្តីតូចតាច។ ដោយឡែកការស្រាវជ្រាវនេះ ជួយបំពេញសកម្មភាពមួយនៃសកម្មភាពទាំងឡាយនៃផែនការសកម្មភាព ដែលចេញពីយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺការងារអាទិភាពរយៈពេលខ្លី (២០០៤-២០០៥) សកម្មភាពទី ៦.២.១ អំពី "សិក្សាស្រាវជ្រាវ កែលំអ និងពង្រឹងយន្តការដោះស្រាយវិវាទតាមប្រពៃណី និងក្រៅតុលាការនានា" ។

តាមរយៈលទ្ធផលនៃការសិក្សានេះបង្ហាញថា អាជ្ញាធរមូលដ្ឋានដើរតួនាទីជាអ្នកដោះស្រាយវិវាទតាមទម្រង់ផ្សេងៗពីគ្នា។ ប្រជាពលរដ្ឋទៅរកអាជ្ញាធរទាំងនោះដោយស្ម័គ្រចិត្ត ហើយអាជ្ញាធរទាំងនោះជាអ្នកជួយសម្រុះសម្រួលគូភាគី ហើយដែលរឿងក្តីភាគច្រើនពួកគេបានឈានដល់ការព្រមព្រៀងគ្នា។ ក្នុងទិដ្ឋភាពភាគច្រើន ប្រជាពលរដ្ឋមានជំនឿច្រើនទៅលើអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយវិវាទរបស់ពួកគេជាងនៅក្នុងតុលាការ ជាពិសេសពីព្រោះអាជ្ញាធរនេះអាចធ្វើការសម្រុះសម្រួលដែលជាកត្តាបន្ថែមលើរឿងដែលថា ប្រជាពលរដ្ឋចំណាយលុយ និងពេលវេលាតិចជាងការដែលទៅរកតុលាការ។ ក្នុងន័យនេះវាមានភាពច្បាស់លាស់សម្រាប់សេចក្តីសន្និដ្ឋាន និងអនុសាសន៍មួយក្នុងចំណោមសេចក្តីសន្និដ្ឋាន និងអនុសាសន៍ទាំងឡាយនៃការសិក្សានេះ គឺការបង្កើតស្ថាប័ន និងពង្រឹងយន្តការផ្សេងៗសម្រាប់ដោះស្រាយនៅថ្នាក់មូលដ្ឋាន ( ភូមិ និងឃុំ) ។ ទោះជាយ៉ាងនេះក្តីវាក៏មានសារៈសំខាន់ផងដែរ ក្នុងការគិតទៅដល់ដែនកំណត់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយពិចារណាពីតម្រូវការយុត្តិធម៌របស់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ព្រោះថាវាមិនមែនជាជំរើសដ៏ល្អបំផុតនោះទេ បើយកករណីទាំងអស់នោះមកដោះស្រាយ តាមយន្តការដោះស្រាយវិវាទក្រៅតុលាការ ពីព្រោះយន្តការនេះមានចំណុចខ្វះខាតច្រើន ទាំងទៅលើចំណុចខ្វះខាតនៃយន្តការខ្លួនឯង និងទៅលើស្ថានភាពនៃការអនុវត្តរាល់ថ្ងៃ។

ជារួមទោះបីជាប្រជាពលរដ្ឋទៅរកអាជ្ញាធរមូលដ្ឋាន គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារក្តីក៏អ្នកជម្រះផ្សា អ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលក្រុមការងារសិក្សាស្រាវជ្រាវបានសម្ភាស បានបង្ហាញពីចំណុចខ្វះខាតនៃប្រព័ន្ធទាំងនេះ ដូចជាៈ ក-អសមត្ថភាពនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងអាជ្ញាធរមូលដ្ឋាន ដើម្បី

ដោះស្រាយវិវាទ និងការពារសិទ្ធិ នៅពេលដែលមានភាគីមួយដែលជាអ្នកមានអំណាច មិនចង់ឈានទៅរកការព្រមព្រៀងគ្នា ខ-អសមត្ថភាពនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងការដាក់ឱ្យអនុវត្តការព្រមព្រៀង នៅពេលដែលគូភាគីបានព្រមព្រៀងគ្នាហើយនោះ តែក្រោយមកមានភាគីម្ខាងមិនចង់បំពេញតាមកិច្ចព្រមព្រៀង គ-កង្វះខាតសមត្ថកិច្ចនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយរឿងមួយចំនួន ដែលត្រូវបានចាត់ទុកថាជារឿងផ្តាច់មុខរបស់តុលាការ ដូចជាការលែងលះ បទល្មើសព្រហ្មទណ្ឌ និងសំណងការខូចខាតដោយសារបទល្មើស និង ឃ-កង្វះគណនេយ្យភាព និងភាពលម្អៀងរបស់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីសុរិយោដី។

ការសន្និដ្ឋានទៅលើអ្វីដែលថា ប្រជាពលរដ្ឋនៅមូលដ្ឋានត្រូវការឱ្យមានយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវតែលើកយកមកសិក្សាវាយតម្លៃម្តងទៀត។ វាហាក់បីដូចជាអ្វីដែលប្រជាពលរដ្ឋត្រូវការទាំងនេះ តម្រូវឱ្យមានការឆ្លើយតបតាមវិធី ឬយន្តការផ្សេងៗ ដោយអាស្រ័យលើចរិតលក្ខណៈនៃវិវាទនិងភាគីដែលជាប់ពាក់ព័ន្ធនឹងវិវាទនោះ។ ដោយសំអាងលើហេតុផលនេះហើយ ទើបវាជាការចាំបាច់បំផុត ដែលត្រូវមានដោយខានពុំបាននូវការសម្របសម្រួល រវាងយន្តការទាំងនេះក្នុងក្របខ័ណ្ឌប្រព័ន្ធយុត្តិធម៌ជាតិ ដែលក្នុងនោះចាំបាច់ត្រូវមានចក្ខុវិស័យជាប្រព័ន្ធមួយ ក្នុងការផ្តល់សេវាយុត្តិធម៌ ដូចជាការបែងចែកមុខងារឱ្យបានច្បាស់លាស់ក្នុងចំណោម (១). ប្រព័ន្ធយុត្តិធម៌ផ្លូវការ (២). យន្តការដោះស្រាយវិវាទក្រៅតុលាការ (៣). យន្តការដោះស្រាយវិវាទក្រៅតុលាការនៅថ្នាក់មូលដ្ឋាន (៤). យុត្តិធម៌មូលដ្ឋាន និង (៥). ច្បាប់សម្រាប់ជនជាតិដើមភាគតិច។

- បង្កើតឱ្យមានយន្តការដ៏ប្រសើរមួយសម្រាប់សម្របសម្រួលក្នុងការផ្តល់សេវាយុត្តិធម៌។
- ពង្រឹងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋាន ជាពិសេសនៅថ្នាក់ភូមិ និងឃុំ ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានរវាងគូភាគីដែលមាន ស្ថានភាពប្រហាក់ប្រហែលគ្នា តាមរយៈការសម្រុះសម្រួល។
- ដាក់ឱ្យមានអំណាចយុត្តាធិការនៅថ្នាក់មូលដ្ឋាន ដែលករណីនេះអាចធ្វើតាមរយៈទម្រង់ជាក្រុមប្រឹក្សាយុត្តិធម៌។
- ពង្រឹងវិធានទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច និងយន្តការដោះស្រាយវិវាទរបស់ពួកគេ នៅក្នុងបណ្តាខេត្តដែលមានសហគមន៍ជនជាតិដើមភាគតិច។
- កែលំអការងាររបស់គណៈកម្មការសុរិយោដីដើម្បីឱ្យមានលទ្ធភាពដោះស្រាយវិវាទដីធ្លីធំៗ ។
- កែលំអក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារដើម្បីអាចទទួលដោះស្រាយវិវាទការងារកាន់តែទូលំទូលាយ ។
- កែលំអតុលាការ។
- កែលំអនគរបាលយុត្តិធម៌ ។
- កែលំអការផ្តល់សេវាច្បាប់ ។
- បង្កើនសមត្ថភាព និងផ្តល់អំណាចដល់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ។

## ២. អនុសាសន៍

### ២.១. ពង្រឹង និងបង្កើតយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានា

#### ២.១.១. ពង្រឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានានៅថ្នាក់មូលដ្ឋាន

យន្តការដោះស្រាយវិវាទនានាគួរតែត្រូវបានពង្រឹងនៅថ្នាក់មូលដ្ឋាន នៅថ្នាក់ភូមិនិងថ្នាក់ឃុំ ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានរវាងគូភាគីក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា តាមរយៈការសម្រុះសម្រួល។

ដើម្បីពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវតែ:

ក- បង្កើតក្របខ័ណ្ឌច្បាប់ សម្រាប់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទូទៅមួយ រួមទាំងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ដោយគិតពិចារណាអំពីមុខងារសម្រុះសម្រួលរបស់ឃុំ ដែលគ្រាន់តែយោងលើអនុក្រឹត្យមួយដោយគ្មានការពន្យល់ច្បាស់លាស់អំពីសមត្ថកិច្ច និងការលាតសន្ធឹងរបស់មុខងារនេះឡើយ។

ខ- ផ្តល់ឱកាសសម្រាប់អ្នកសម្របសម្រួលសេវាយុត្តិធម៌ ក៏ដូចជាសម្រាប់ការដាក់ពាក្យប្តឹង។ បើមិនដូច្នោះទេ អ្នកក្រីក្រត្រូវទទួលបន្ទុកក្នុងការចំណាយលើរឿងនេះ ឬការបង់ថ្លៃនេះអាចជាប្រភពមួយនៃអំពើពុករលួយ ។

គ- បណ្តុះបណ្តាលអ្នកផ្សះផ្សាឱ្យបានត្រឹមត្រូវ។ ការបណ្តុះបណ្តាលត្រូវរួមបញ្ចូលនូវ: ១-បច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ២-សិទ្ធិស្ត្រី និងកុមារ ៣-សិទ្ធិលើដីធ្លី ៤-ព័ត៌មានទូទៅអំពីច្បាប់ និងវចនាសម្ព័ន្ធសមត្ថកិច្ចតុលាការ។ល។ និង ៥-បញ្ហាដែលពាក់ព័ន្ធនឹងនីតិវិធី (របៀបដាក់ពាក្យបណ្តឹង មានពេលកំណត់ក្នុងការដោះស្រាយ...ល។) និង

ឃ- បង្កើតយន្តការសម្រាប់ត្រួតពិនិត្យ និងធានាឱ្យមានគណនេយ្យភាព ដោយគិតទៅដល់ថាវិវាទភាគច្រើនដែលមាននៅថ្នាក់មូលដ្ឋានគឺទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារនិងដីធ្លី ដូចនេះការបណ្តុះបណ្តាលអាចបញ្ចូលព័ត៌មានអំពីសិទ្ធិពាក់ព័ន្ធនឹងរឿងទាំងនេះ។ ធ្វើដូច្នេះ អាជ្ញាធរមូលដ្ឋាន ឬអ្នកសម្រុះសម្រួលនឹងអាចបង្កាពីការដោះស្រាយដោយភាពអយុត្តិធម៌ ហើយបញ្ជូនរឿងក្តីទាំងនោះទៅអាជ្ញាធរដែលមានសមត្ថកិច្ចត្រឹមត្រូវ។

## ២.១.២. បង្កើតអំណាចយុត្តាធិការឱ្យនៅជិតប្រជាពលរដ្ឋ: យុត្តិធម៌នៅមូលដ្ឋាន

អ្នកចូលរួមក្នុងសិក្ខាសាលាបានបង្ហាញពីទស្សនៈរបស់ពួកគេ ពីប្រព័ន្ធយុត្តិធម៌នៅមូលដ្ឋាន លើចំណុចជាក់លាក់មួយចំនួនដូចជា:

ក- ភាពងាយស្រួលក្នុងការទទួលយកសេវា: ភូមិសាស្ត្រ (ភាពនៅជិត) សេដ្ឋកិច្ច (តម្លៃទាប) ភាសា និងសង្គមវប្បធម៌ (អាចយល់បាន)។

ខ- នីត្យានុកូលភាព: អាជ្ញាធរដែលដោះស្រាយវិវាទ ត្រូវតែបានទទួលស្គាល់តាមផ្លូវច្បាប់ ដោយមានសមត្ថកិច្ចច្បាស់លាស់ក្នុងការដោះស្រាយវិវាទមួយចំនួន។

គ- រឿងក្តីខ្លះដូចជាការលែងលះ ឬសំណងការខូចខាតសម្រាប់រឿងក្តីព្រហ្មទណ្ឌមួយចំនួន គួរតែត្រូវបានដោះស្រាយ នៅថ្នាក់មូលដ្ឋាន ដោយអាជ្ញាធរស្របច្បាប់ដែលមានអំណាចយុត្តាធិការ។

ឃ- ប្រសិទ្ធិភាពក្នុងការដោះស្រាយវិវាទ ការពារសិទ្ធិ និងត្រួតពិនិត្យការរំលោភអំណាច។

ង- ការចូលរួមពីគូភាគី នៅក្នុងដំណើរការដោះស្រាយវិវាទទាំងមូល ពីពេលចាប់ផ្តើមដំបូងរហូតដល់សេចក្តីសម្រេចចុងក្រោយ។ ពិតមែនតែប្រជាជនបានសង្កត់ធ្ងន់ពីសារៈសំខាន់ នៃដំណើរការសម្រុះសម្រួលនៅក្នុងការដោះស្រាយវិវាទ ប៉ុន្តែប្រសិនបើមានភាគីណាមួយ មិនចង់ឈានដល់ការព្រមព្រៀងទេនោះ ភាគីម្ខាងទៀតអាចទាមទារឱ្យអាជ្ញាធរដោះស្រាយរឿងនេះនៅថ្នាក់មូលដ្ឋានបាន។

ច- ការដាក់ឱ្យអនុវត្ត: សមត្ថកិច្ចក្នុងការដាក់ឱ្យអនុវត្តការព្រមព្រៀង ឬសេចក្តីសម្រេចទានា។

ឆ- យកចិត្តទុកដាក់លើរឿងវប្បធម៌ ភាសា និងយេនឌ័រ។

ជ- ធម្មានុរូបភាព: អាជ្ញាធរទទួលបន្ទុកដោះស្រាយវិវាទ គួរតែឯករាជ្យ មិនរើសអើង អនាគតិ និងមិនលម្អៀង។

ឈ- គណនេយ្យភាព: ត្រូវតែមានមធ្យោបាយក្នុងការត្រួតពិនិត្យការអនុវត្តរបស់អាជ្ញាធរយុត្តាធិការ និងទប់ស្កាត់អំពើពុករលួយ។

ក- ពង្រឹងមុខងារសម្រុះសម្រួលនៅថ្នាក់មូលដ្ឋាន: ការពង្រឹងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ពិតជាមានសារៈសំខាន់ ដើម្បីឱ្យគេដោះស្រាយវិវាទនៅតាមមូលដ្ឋាន រវាងគូភាគីដែលស្ថានភាពសង្គមប្រហាក់ប្រហែលគ្នា។ ក្នុងន័យនេះ អ្នកដែលដើរតួជាអ្នកសម្រុះសម្រួល គួរតែត្រូវបានបណ្តុះបណ្តាលជាប្រចាំ ឱ្យធ្វើកិច្ចការនេះកាន់តែប្រសើរឡើង។ បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំ និងមេភូមិ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួល ហេតុនេះពួកគេគួរតែត្រូវបានបណ្តុះបណ្តាលសម្រាប់បំពេញមុខងារដ៏សំខាន់នេះ។ ការនេះទាមទារឱ្យមានអង្គភាពឯករាជ្យមួយ ដែលមិនពាក់ព័ន្ធនឹងគណៈបក្សនយោបាយ ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាននៅក្នុងពេលអនាគត។

ខ- ចៀសវាងការប្រកាន់បក្សនយោបាយក្នុងការដោះស្រាយវិវាទ: ដំណើរការសម្រុះសម្រួល និងការដោះស្រាយវិវាទ គួរតែធ្វើឡើងដោយដាច់ស្រឡះពីឥទ្ធិពលគណបក្សនយោបាយ ដូចដែលអ្នកចូលរួមក្នុងសិក្ខាសាលាជាច្រើនបានសំណូមពរ។ អ្នកខ្លះបានស្នើឱ្យមានការបោះឆ្នោត ជ្រើសរើសអង្គភាពត្រួតពិនិត្យដើម្បីពិនិត្យកិច្ចការនេះ។ ការិយាល័យនេះគួរតែមានអ្នកបំម្រើការ ដែលត្រូវបានជ្រើសរើសដោយផ្អែកលើកិត្តិយសរបស់បុគ្គលម្នាក់ៗ ជាជាងជ្រើសរើសតាមបញ្ជីឈ្មោះរបស់គណបក្សនយោបាយ។

គ- ធានាគណនេយ្យភាព: អ្នកទាំងអស់ដែលចូលរួមធ្វើការងារនេះ ត្រូវទទួលខុសត្រូវចំពោះខ្សែទទឹង និងខ្សែបណ្តោយរបស់ខ្លួន តាមរយៈយន្តការជាក់លាក់មួយដែលត្រូវបានគេបង្កើតឡើង។ គេត្រូវមានគណនេយ្យភាពចំពោះស្ថាប័ន និងសង្គម។

ឃ- បង្វិលអំណាចយុត្តាធិការឱ្យទៅជិតប្រជាពលរដ្ឋ: អ្នកចូលរួមក្នុងសិក្ខាសាលាបានបង្ហាញពីភាពចាំបាច់នៃការទទួលស្គាល់ដោយច្បាប់ចំពោះប្រព័ន្ធយុត្តិធម៌នៅតាមមូលដ្ឋាន ដើម្បីឱ្យគេអាចធ្វើជាភ្នាក់ងារក្នុងការសម្រុះសម្រួលរវាងគូភាគី ហើយថែមទាំងមានសមត្ថកិច្ចផ្លូវច្បាប់ក្នុងការសម្រេចសេចក្តីផង។ អាជ្ញាធរនេះគួរតែមានសមត្ថកិច្ចផ្លូវច្បាប់ ហួសពីការជួយសម្រុះសម្រួលដល់ភាគី ដោយគេអាចចេញជាសេចក្តីសម្រេចផ្តល់សិទ្ធ (សិទ្ធិស្ត្រី និងកុមារ) អនុវត្តកិច្ចព្រមព្រៀង ឬសេចក្តីសម្រេច និងការពារការរំលោភអំណាចបានថែមទៀតផង។ម្យ៉ាងទៀតអាជ្ញាធរនេះគួរតែត្រូវបានជ្រើសរើសដោយការបោះឆ្នោតនៅមូលដ្ឋាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋដែលផ្តល់អំណាចឱ្យខ្លួន។

*ក្រុមប្រឹក្សាយុត្តិធម៌* ( *Justice Council* )

តម្រូវការនេះមានន័យថា ចាំបាច់ត្រូវដាក់ឱ្យមានអំណាចយុត្តាធិការ ឱ្យទៅជិតប្រជាពលរដ្ឋនៅថ្នាក់ស្រុក ឬឃុំ។ អ្នកចូលរួមសិក្ខាសាលា និងអ្នកដែលត្រូវបានសម្ភាសបានឱ្យយោបល់ថា អាជ្ញាធរដែលមានយុត្តាធិការ អាចជាក្រុមប្រឹក្សាមួយ (ប្រហែលជាយកបទពិសោធន៍ពីក្រុមប្រឹក្សាឃុំបច្ចុប្បន្ន) ប៉ុន្តែសមាជិកនៃក្រុមប្រឹក្សានេះ ត្រូវតែជាសមាជិកឯករាជ្យ (ដែលមិនមែនតំណាងឱ្យគណបក្សនយោបាយទេ) និងយ៉ាងហោចមានស្ត្រីម្នាក់ ដើម្បីលើកតម្កើងសមភាពយេនឌ័រ។ វាត្រូវមានរចនាសម្ព័ន្ធជាក្រុមប្រឹក្សា ឬជាអង្គជំនុំជំរះ ជាជាងការសម្រេចសេចក្តីដោយមនុស្សតែម្នាក់ ដែលអាចនឹងធ្វើឱ្យការសម្រេចរបស់គេកាន់តែមានតម្លាភាព។ អ្នកចូលរួមក៏បានឱ្យយោបល់ថា អង្គភាពនេះអាចអនុវត្តទំនៀមទម្លាប់នៅមូលដ្ឋាន ប្រើប្រាស់ភាសាមូលដ្ឋាន និងមាននីតិវិធីសាមញ្ញងាយយល់។ ក្នុងន័យនេះវាអាចមិនមែនជាតុលាការផ្លូវការ ឬបំរើការងារដោយអ្នកច្បាប់នោះទេ។ ហេតុដូច្នេះ ទោះបីជា*ក្រុមប្រឹក្សាយុត្តិធម៌*នេះអាចមានអំណាចយុត្តាធិការ វាត្រូវមាននីតិវិធីសាមញ្ញ និងអាចដោះស្រាយរឿងក្តីយោងតាមសមធម៌ និងទំនៀមទម្លាប់នៅមូលដ្ឋាន ព្រមទាំងការពារសិទ្ធិដែរ។

ការបំពេញការងាររបស់នគរបាលនៅថ្នាក់មូលដ្ឋាន គួរតែធ្វើឡើងក្រោមការត្រួតពិនិត្យរបស់ប្រព័ន្ធយុត្តិធម៌នៅមូលដ្ឋាន ដើម្បីការពារសិទ្ធិប្រជាពលរដ្ឋ និងធានានូវតម្លាភាព។ អាជ្ញាធរដែលមានអំណាចយុត្តាធិការនៅថ្នាក់មូលដ្ឋាន ត្រូវតែផ្តល់ថវិកាដោយរដ្ឋ និងឆ្លើយតបទៅនឹងក្រមសីលធម៌ និងប្រព័ន្ធត្រួតពិនិត្យ។

ដូចមាននៅក្នុងប្រទេសជាច្រើនទៀតដែរ អ្នករស់នៅក្នុងភូមិ និងឃុំ អាចបោះឆ្នោតរើសចៅក្រមសន្តិភាពថ្នាក់ឃុំ (Justices of the peace) ផ្អែកលើស្ថានភាពរូបវន្តរបស់ពួកគេ។ ពួកគេត្រូវតែឯករាជ្យពីអំណាចនយោបាយ ហេតុនេះពួកគេមិនគួរត្រូវបានតែងតាំងដោយរដ្ឋាភិបាល ឬមិនត្រូវបានបោះឆ្នោតតាមរយៈប្រព័ន្ធគណបក្សនយោបាយទេ។ ដើម្បីបង្ការការប្រមូលផ្តុំអំណាច អាជ្ញាធរដែលមានអំណាចយុត្តាធិការទាំងនេះ គួរតែត្រូវបានផ្លាស់ប្តូរក្នុងរយៈពេលពី ពីរ ទៅបីឆ្នាំម្តង។

## ២.១.៣. ទទួលស្គាល់ និងពង្រឹងច្បាប់ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេ

### ២.១.៣.១. ទទួលស្គាល់ និងពង្រឹងច្បាប់ជនជាតិដើមភាគតិច

ក. ទទួលស្គាល់អាជ្ញាធរជនជាតិដើមភាគតិចក្នុងការដោះស្រាយវិវាទ។ ទទួលស្គាល់ដោយពេញលេញចំពោះច្បាប់ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច និងយន្តការដោះស្រាយវិវាទរបស់ពួកគេសម្រាប់ដោះស្រាយវិវាទដែលកើតមាននៅក្នុង និងរវាងសហគមន៍ជនជាតិដើមភាគតិច ព្រមទាំងនៅក្រៅសហគមន៍ជនជាតិដើមភាគតិច បើវិវាទនោះពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។

ខ. ពិចារណាលើរចនាសម្ព័ន្ធរបស់ជនជាតិដើមភាគតិចក្នុងការធ្វើវិមជ្ឈការ ក្នុងវិស័យអភិបាលកិច្ច យុត្តិធម៌ និងការផ្តល់សេវាសាធារណៈ។

គ. អនុវត្តច្បាប់ភូមិបាលឱ្យមានប្រសិទ្ធិភាព។ ច្បាប់ភូមិបាលនាពេលបច្ចុប្បន្ន (ឆ្នាំ ២០០១) ទទួលស្គាល់អាជ្ញាធរ ទំនៀមទម្លាប់ និងយន្តការនៃការធ្វើសេចក្តីសម្រេច របស់សហគមន៍ជនជាតិដើមភាគតិច ទាក់ទិននឹងការគ្រប់គ្រងដីសមូហភាព (មាត្រា ២៣)។ បញ្ញត្តិនេះអាចរាប់បញ្ចូលទាំងយន្តការដោះស្រាយវិវាទដែលយ៉ាងហោចណាស់សម្រាប់វិវាទដីធ្លីដែរ។

ឃ. ផ្តល់សច្ចាប័នចំពោះអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ នៅក្នុងប្រទេសឯករាជ្យ។

ង. គោរពតាមបទបញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ភូមិបាល ដោយគោរពតាមវិធានទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច អាជ្ញាធរប្រពៃណី និងដំណើរការធ្វើសេចក្តីសម្រេចរបស់ពួកគេ។

### ២.១.៣.២. គោរពសិទ្ធិរបស់ជនជាតិដើមភាគតិចនៅចំពោះមុខតុលាការ និងនីតិវិធីច្បាប់

ក. គោរពសិទ្ធិទាំងឡាយដូចដែលកម្ពុជាបានទទួលស្គាល់រួចហើយ។ គោរពសិទ្ធិទាំងឡាយដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា ២៧) ទាក់ទងនឹងការប្រើប្រាស់ភាសារបស់ជនជាតិដើមភាគតិច និងការអនុវត្តនូវជំនឿ និងសាសនារបស់ពួកគេ[២៣១]។

ខ. ការអនុវត្តនូវសិទ្ធិវប្បធម៌ និងភាសានៅក្នុងការផ្តល់ និងទទួលយកសេវាសាធារណៈទាំងឡាយ ដូចជា អប់រំ សុខាភិបាល និងសេវាផ្សេងៗទៀត ។

---

[២៣១] មាត្រា ២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា ក្នុងរដ្ឋទាំងឡាយដែលជាសមាជិកនៃកតិកាសញ្ញានេះ តែងតែមានប្រជាពលរដ្ឋភាគតិចសព្វបែបយ៉ាង ទាំងក្នុងវិស័យសាសនា និងវិស័យភាសា។ មនុស្សដែលជាសមាជិកនៃសង្គមភាគតិច ទាំងនេះមានសិទ្ធិក្នុងការគោរពទំនៀមទម្លាប់វប្បធម៌ខ្លួន សិទ្ធិក្នុងការគោរព និងប្រារព្ធពិធីសាសនាខ្លួន ព្រមទាំងសិទ្ធិក្នុងការប្រើប្រាស់ភាសាកំណើតរបស់ខ្លួនទាំងនៅក្នុងសហគមន៍ខ្លួន ទាំងជាមួយសមាជិកដទៃទៀត

គ. អនុវត្តច្បាប់ភូមិបាលសម្រាប់ការធ្វើចំណាត់ថ្នាក់ដី កំណត់ព្រំប្រទល់ដីធ្លី និងការចុះបញ្ជីដីធ្លី ។

ឃ. អនុវត្តឱ្យបានពេញលេញនូវមុខងាររបស់គណៈកម្មការសុរិយោដី ក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងការទន្ទ្រានយកដីធ្លី។

ង. អនុវត្តនូវការការពារទ្រព្យសម្បត្តិសមូហភាព របស់ជនជាតិដើមភាគតិច ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ ចាប់ពីមាត្រា ២៣ ដល់មាត្រា ២៨។

ច. ការពារជីវិតរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈតុលាការ។ ត្រូវមានការការពារតាមផ្លូវតុលាការ ដើម្បីកុំឱ្យមានការទន្ទ្រានយកដីធ្លីខុសច្បាប់ ដែលអាចឈានទៅដល់ការកាប់ឆ្ការព្រៃលើដីធ្លី និងប៉ះពាល់ដល់ជីវិតរបស់ជនជាតិដើមភាគតិច។

ឆ. ត្រូវផ្តល់អ្នកច្បាប់ជួយការពារ និងអ្នកបកប្រែភាសាសម្រាប់ជនជាតិដើមភាគតិចណា ដែលប្រឈមនឹងការជំនុំជំរះតាមផ្លូវតុលាការ ឬនីតិវិធីច្បាប់ផ្សេងៗទៀត ។

ជ. បញ្ចូលនូវវិធានការជំនួសពន្ធនាគារផ្សេងៗ នៅក្នុងក្រមព្រហ្មទណ្ឌ រួមទាំងការធ្វើការងារឱ្យសហគមន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិចជាដើម ។

២.១.៣.៣. បង្កើតឱ្យមានប្រព័ន្ធសម្របសម្រួល

ក. បន្ទាប់ពីមានដំណើរការពិគ្រោះយោបល់ហើយ ត្រូវមានការសម្របសម្រួលរវាងប្រព័ន្ធដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច និងប្រព័ន្ធដោះស្រាយវិវាទរបស់ជាតិ។

ខ. ត្រូវមានយន្តការមួយ ដើម្បីដោះស្រាយវិវាទលើសមត្ថកិច្ចរវាងយន្តការដោះស្រាយវិវាទផ្សេងៗ និងវិវាទពាក់ព័ន្ធនឹងការរំលោភសិទ្ធិបុគ្គល បន្ទាប់ពីមានដំណើរការពិគ្រោះយោបល់រួចហើយ ដើម្បីឱ្យមានច្បាប់ចែងអំពីការទទួលស្គាល់យន្តការដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច ដោយមានការសម្របសម្រួលជាមួយតុលាការ គណៈកម្មការសុរិយោដី និងស្ថាប័នសាធារណៈផ្សេងៗទៀត។

គ. កែលំអ និងអនុម័តសេចក្តីព្រាងគោលនយោបាយស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនជាតិដើមភាគតិច និងនិយាមអន្តរជាតិ បន្ទាប់ពីមានការពិគ្រោះយោបល់ស៊ីជំរៅជាមួយជនជាតិដើមភាគតិចរួចមក។

២.១.៣.៤. បង្កើនសមត្ថភាព និងផ្តល់អំណាចឱ្យជនជាតិដើមភាគតិច

ក. ពង្រឹង ផ្តល់អំណាច និងបង្កើនការយល់ដឹង ព្រមទាំងកសាងសមត្ថភាព ជូនដល់ជនជាតិដើមភាគតិច រួមទាំងសហគមន៍ និងអង្គការជនជាតិដើមភាគតិច។

ខ. ផ្តល់អំណាច និងបង្កើនសមត្ថភាពរបស់ជនជាតិដើមភាគតិចក្នុងការដោះស្រាយវិវាទ ដែលកើតមាននៅក្នុង និងរវាងសហគមន៍ជនជាតិដើមភាគតិច។

គ. បង្កើនសមត្ថភាព និងផ្តល់អំណាចឱ្យស្ត្រីជនជាតិដើមភាគតិច ចាស់ទុំ និងសមាជិកសហគមន៍ក្មេងៗទាំងឡាយ ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងសកម្មភាពរបស់សង្គមស៊ីវិលនានា ជាប្រយោជន៍ដល់ការកែលំអសិទ្ធិទទួលបានយុត្តិធម៌។

ឃ. ពង្រឹងធម្មានុរូបភាព និងប្រសិទ្ធិភាពរបស់អាជ្ញាធរជនជាតិដើមភាគតិច។

## ២.២. កែលំអយន្តការដោះស្រាយវិវាទក្រៅតុលាការ

### ២.២.១. គណៈកម្មការសុរិយោដី

ក- ត្រូវបង្កើតគណៈកម្មការសុរិយោដី ឱ្យបានចប់សព្វគ្រប់និងពេញលេញ ក្នុងន័យប្រតិបត្តិការងារស្ថាប័នកសាងសមត្ថភាព និងការផ្សព្វផ្សាយអំពីគណៈកម្មការសុរិយោដីដល់សាធារណៈជន។

ខ- បង្កើនសមត្ថភាពបុគ្គលិក ដោយបណ្តុះបណ្តាលជាប្រចាំនូវបច្ចេកទេសសម្រុះសម្រួល និងច្បាប់ភូមិបាល។ បង្កើនប្រាក់បៀវត្សរ៍ និងបង្កើតយន្តការត្រួតពិនិត្យមួយជាអចិន្ត្រៃយ៍។

គ- ផ្សព្វផ្សាយជាប្រចាំអំពីច្បាប់ភូមិបាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា អ្នកភូមិ សហគមន៍ និងជនជាតិដើមភាគតិច។

ឃ-កំណត់ការកម្រិតពេលវេលា ដើម្បីបង្កើនប្រសិទ្ធិភាព និងតម្លាភាពក្នុងការដោះស្រាយវិវាទ។ ត្រូវតែមានការកម្រិតពេលសមរម្យពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត និងពេលវេលារួមសម្រាប់គណៈកម្មការសុរិយោដីក្នុងការចេញសេចក្តីសម្រេចចុងក្រោយ។ ប្រសិនបើគ្មានការសម្រេចធ្វើឡើងតាមពេលដែលបានកំណត់ទេ គូភាគីគួរតែអាចទៅរកអាជ្ញាកណ្តាល ឬតុលាការបាន។

ង- បង្កើតនីតិវិធី និងពេលវេលាច្បាស់លាស់សម្រាប់ការត្រួតពិនិត្យ លើករណីដែលត្រូវបដិសេធដោយគណៈកម្មការសុរិយោដី។ ករណីដែលគណៈកម្មការសុរិយោដី បដិសេធមិនព្រមចាត់ការលើរឿងក្តី ដែលបានប្តឹងមកនោះ គួរតែត្រូវបានពិនិត្យឡើងវិញដោយតុលាការ។ អនុក្រឹត្យដែលប្រើប្រាស់ជាធរមាននាពេលបច្ចុប្បន្ន បានចែងថាការបដិសេធរឿងក្តី ដោយគណៈកម្មការសុរិយោដី ត្រូវធ្វើឡើងឱ្យស្របច្បាប់។ ច្បាប់ក៏បានចែងផងដែរថាគ្រប់ករណីនៃការបដិសេធនេះ ភាគីអាចប្តឹងទៅគណៈកម្មការសុរិយោដីខេត្ត បាន។ ដើម្បីធានានូវតម្លាភាព រាល់សេចក្តីសម្រេចបដិសេធរឿងក្តី ក៏ដូចជាសេចក្តីសម្រេចចុងក្រោយលើវិវាទគួរតែធ្វើឡើងជាសាធារណៈ និងអនុញ្ញាតឱ្យតុលាការអាចយករឿងនោះ មកពិចារណាឡើងវិញ បាន។

ច- ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីបញ្ឈប់ការបណ្តេញចេញដោយបង្ខំ ការកាប់បំផ្លាញព្រៃឈើ និងសកម្មភាពហិង្សាដទៃៗទៀត បើពុំដូច្នោះទេ ការខូចខាតនឹងមានទ្រង់ទ្រាយកាន់តែធំមិនអាចជួសជុលវិញបានឡើយ។ តាមច្បាប់ គណៈកម្មការសុរិយោដីមានសិទ្ធិទប់ស្កាត់នូវរាល់សកម្មភាពទាំងនេះ ដូចនេះច្បាប់គួរតែត្រូវបានគេអនុវត្តឱ្យមានប្រសិទ្ធិភាព។ ហើយបើសិនជាគណៈកម្មការសុរិយោដីខកខានមិនបានចាត់វិធានការដើម្បីការពារសិទ្ធិរបស់ភាគីបានទេ នោះតុលាការត្រូវធានាការពារសិទ្ធិទាំងនោះ ដើម្បីទប់ស្កាត់ស្ថានភាពដែលមិនអាចជួសជុលឬដោះស្រាយបាន។ ត្រូវតែមានការធានាសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋនៅពេលដែលគណៈកម្មការសុរិយោដីខកខានមិនបានការពារសិទ្ធិទាំងនេះ។

ឆ- បង្កើតនូវយន្តការដើម្បីធានានូវគណនេយ្យភាពសង្គមនៅក្នុងប្រព័ន្ធនេះ ដោយមានការចូលរួមពីសង្គមស៊ីវិល រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ។

ជ- ដោយគណៈកម្មការសុរិយោដី អាចដោះស្រាយដោយមានប្រសិទ្ធិភាពតែលើវិវាទដីធ្លីទាំងឡាយណា ដែលភាគីមានស្ថានភាពប្រហាក់ប្រហែលគ្នាតែប៉ុណ្ណោះនោះ ដូចនេះត្រូវតែមានច្បាប់ចែងអំពីយន្តការក្នុងការការពារ សិទ្ធិលើដីធ្លី នៅពេលដែលគូភាគីទាំងនោះឋិតក្នុងស្ថានភាពអតុល្យភាពអំណាច។

ឈ -ត្រូវអនុម័តច្បាប់រៀបចំអង្គការ ស្តីពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលចែងអំពីប្រភេទផ្សេងៗនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (រួមទាំងយន្តការដោះស្រាយវិវាទក្នុងសហគមន៍) ព្រមទាំងកំណត់អំពីសុពលភាពលើសេចក្តីសម្រេចរបស់យន្តការទាំងនោះនៅចំពោះមុខតុលាការ ព្រមទាំងការអនុវត្តសេចក្តីសម្រេចរបស់ប្រព័ន្ធទាំងនេះ និងការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការលើសេចក្តីសម្រេចទាំងនោះ ។

### ២.២.២. ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ

- ពង្រីកក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារឱ្យមានច្រើនថែមទៀត នៅតាមបណ្តាលខេត្តមួយចំនួន ជាពិសេសនៅខេត្តទាំងឡាយណា ដែលមានកម្មករ-និយោជិកច្រើននៅតាមសហគ្រាស និងចំការធំៗ ដូចជានៅខេត្តកំពង់ចាម ក្រុងព្រះសីហនុ និងខេត្តសៀមរាបជាដើម ។
- ត្រូវធានាឱ្យមានការអប់រំ និងការផ្សព្វផ្សាយច្បាប់ដល់ទូទាំងសហគមន៍ទាំងមូល ជាពិសេសនៅតំបន់ក្នុងខេត្តមួយចំនួនដែលមានចំការធំៗនៅតាមជនបទ ហើយមានកម្មករ-និយោជិកបំរើការនៅទីនោះ ។
- រដ្ឋត្រូវផ្តល់ថវិកាសម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធានាដល់និរន្តរភាពរបស់ក្រុមប្រឹក្សា ។
- បន្ទាប់ពីមានការពិគ្រោះយោបល់ហើយ ត្រូវបង្កើតយន្តការដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោយផ្ទាល់ចំពោះគូភាគីវិវាទ ។
- កែលំអ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវច្បាប់ស្តីពីការងារ ក្រោយពីមានការពិគ្រោះយោបល់ ។
- បន្ថែមអាណត្តិ របស់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ ឱ្យមានរយៈពេលយ៉ាងហោចណាស់បីឆ្នាំក្នុងមួយអាណត្តិ ។ អាណត្តិមួយឆ្នាំដូចបច្ចុប្បន្ននេះវាខ្លីពេកសម្រាប់ការបំពេញការងាររបស់អាជ្ញាកណ្តាល និងកសាងបទពិសោធន៍ការងារដ៏មានតម្លៃនោះទេ ។ អនុសាសន៍នេះត្រូវបានលើកឡើងដោយអ្នកចូលរួមសិក្ខាសាលាមួយចំនួន តែមិនមានការចូលរួមយោបល់ពីអ្នកដទៃទៀតទេ ។

## ២.៣. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ផ្លូវការ

### ២.៣.១. អនុសាសន៍

ក. បង្កើនសមត្ថភាពជំនាញនៅក្នុងវិស័យយុត្តិធម៌ (ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី) រួមទាំងតម្លើងប្រាក់បៀវត្ស៍ និងលក្ខខណ្ឌការងាររបស់ក្រឡាបញ្ជី ។

ខ. បំពេញនូវក្របខ័ណ្ឌច្បាប់ឱ្យបានចប់សព្វគ្រប់ ។

គ. អនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារដល់ជនរងគ្រោះឱ្យមានប្រសិទ្ធិភាពបំផុត ។ យកចិត្តទុកដាក់លើតម្រូវការនិងសិទ្ធិរបស់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានខាងផ្លូវភេទ ។

ឃ. គោរព និងអនុវត្តរដ្ឋធម្មនុញ្ញ (ការពិគ្រោះជំងឺដោយឥតគិតថ្លៃសម្រាប់អ្នកក្រីក្រ) និងច្បាប់នីតិវិធីព្រហ្មទណ្ឌ (ជនរងគ្រោះមិនតម្រូវឱ្យបង់ប្រាក់ សម្រាប់ធ្វើកោសល្យវិច្ច័យឡើយ) ព្រមទាំងធានាដល់ការលុបបំបាត់នូវកម្រៃសម្រាប់ការធ្វើកោសល្យវិច្ច័យដែលជនរងគ្រោះត្រូវបង់ ។ គួរតែមានការសហការ និងសម្របសម្រួលអន្តរស្ថាប័ន រវាងតុលាការជាមួយក្រសួងសុខាភិបាល ដើម្បីបញ្ឈប់ការទាមទារឱ្យជនរងគ្រោះបង់ប្រាក់ថ្លៃធ្វើកោសល្យវិច្ច័យ បើសិនជាជនរងគ្រោះនោះត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា និងនគរបាល ។ បើពុំនោះទេ

ការចំណាយលើកោសល្យវិច្ច័យនេះ គួរតែបញ្ចូលទៅក្នុងកញ្ចប់ថវិការបស់ស្ថាប័នពាក់ព័ន្ធណាមួយដើម្បីចៀសវាងការតម្រូវឱ្យជនរងគ្រោះបង់ប្រាក់ធ្វើកោសល្យវិច្ច័យនេះ ។

ង. បង្កើតយន្តការមួយដើម្បីធានាថា ជនរងគ្រោះ ពិតជានឹងបានទទួលសំណងជួសជុលការខូចខាត ។

ច. បង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជន ។ ដូចនេះអនីតិជន គួរតែទទួលនូវការយកចិត្តទុកដាក់ដ៏សមរម្យមួយ និងការការពារសិទ្ធិរបស់ពួកគេផងដែរ ។ ដាក់ឱ្យមានយន្តការដាក់ទណ្ឌកម្មក្រៅពីពន្ធនាគារសម្រាប់អនីតិជនដែលប្រព្រឹត្តិបទល្មើស ។

ឆ. បង្កើតឱ្យមានតុលាការជំនាញនានា ដើម្បីលើកតម្កើងឱ្យមានចំណេះដឹងកាន់តែខ្ពស់ តែត្រូវគោរពឯករាជ្យភាពនៃស្ថាប័នដែលមានយុត្តាធិការ ។

ជ. វាយតម្លៃលើការបង្កើតតុលាការគ្រួសារចល័ត ឬនៅជិតនឹងថ្នាក់មូលដ្ឋាន ។ បន្ថែមលើនេះទៅទៀត ត្រូវផ្តល់អំណាចយុត្តាធិការដល់ប្រព័ន្ធយុត្តិធម៌មូលដ្ឋាន (អាចនៅថ្នាក់ឃុំ ឬថ្នាក់ស្រុក) ដើម្បីឱ្យអង្គភាពយុត្តិធម៌នៅថ្នាក់នេះអាចមានសមត្ថភាពផ្លូវច្បាប់ ក្នុងការធ្វើអន្តរាគមន៍លើរាល់បញ្ហាពាក់ព័ន្ធរឿងគ្រួសារ រួមទាំងអំពើហិង្សាក្នុងគ្រួសារ ការផ្តាច់សង្វាសនូវចំណងអាពាហ៍ពិពាហ៍តាមប្រពៃណី ក៏ដូចជាការធានាសិទ្ធិកុមារ និងសិទ្ធិស្ត្រីផងដែរ ។

ឈ.បង្កើតឱ្យមានយន្តការពិសេសមួយ ដើម្បីធានានូវការគោរពសិទ្ធិទាំងឡាយ ដែលធានាដោយរដ្ឋធម្មនុញ្ញឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាព ។

ញ. ពង្រឹងស្ថាប័នតុលាការឱ្យមានសមត្ថភាពដោះស្រាយ (១).រឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ (២). ករណីរដ្ឋប្បវេណីដែលតម្រូវឱ្យដោះស្រាយតាមផ្លូវតុលាការ (៣). ការពារសិទ្ធិមនុស្ស និង (៤). ករណីទាក់ទិននឹងការរំលោភអំណាច ។

ដ. ធ្វើវិមជ្ឈការ និងវិសហមជ្ឈការដោយយកចិត្តទុកដាក់ក្នុងផ្ទេរអំណាចយុត្តាធិការ ក្នុងការដោះស្រាយវិវាទទៅឱ្យថ្នាក់ក្រោម ឬមូលដ្ឋាន ព្រមទាំងមានការទទួលស្គាល់ឱ្យកាន់តែទូលំទូលាយចំពោះយន្តការដោះស្រាយវិវាទរបស់សហគមន៍ជនជាតិដើមភាគតិច ។

ឋ. បញ្ចូលនូវយន្តការ ឬវិធានការផ្សេងៗនៅក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីសម្រេចឱ្យបាននូវគោលដៅនៃដំណើរការក្តីព្រហ្មទណ្ឌ ដោយចៀសវាងការជំនុំជំរះ ឬការដាក់ពន្ធនាគារក្នុងករណីដែលពុំចាំបាច់ ។ ក្នុងចំណោមវិធានការទាំងនេះមានដូចជា: គោលការណ៍ផ្តល់ឱកាសឱ្យភាគីក្នុងការចរចារដើម្បីដោះស្រាយរឿងក្តី (plea-bargaining and principle of opportunity) វិធានការជំនួសពន្ធនាគារ (alternatives to prison) វិធានក្រមសីលធម៌ (rules of conduct) និងវិធានការដទៃៗទៀត ដើម្បីអនុញ្ញាតឱ្យមានការដោះស្រាយដោយស្របច្បាប់ និងមានការបង់នូវសំណងជួសជុលការខូចខាតជូនដល់ជនរងគ្រោះ ។ វិធានការជំនួស ឬក្រៅតុលាការទាំងនេះត្រូវតែធ្វើឡើងដោយមានតម្លាភាព និងស្ថិតក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរមានយុត្តាធិការនិងសមត្ថកិច្ច ។ ការដែលធ្វើដូចនេះអាចជួយសម្រាលដល់បន្ទុករបស់តុលាការនិងពន្ធនាគារ ព្រមទាំងឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពចំពោះអ្វីដែលជាតម្រូវការរបស់សង្គម ។

ឌ. បង្កើននូវតម្លាភាព និងត្រួតពិនិត្យអំពើពុករលួយក្នុងការផ្តល់សេវាកម្មយុត្តិធម៌ ។

### ២.៣.២. នគរបាលយុត្តិធម៌

ក. បន្ថែមសមត្ថភាពជំនាញរបស់នគរបាល ក៏ដូចជាបន្ថែមប្រាក់បៀវត្សរ៍ និងកែលំអលក្ខខណ្ឌការងាររបស់គេ។

ខ. ផ្តល់ការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។

គ. កែលំអបញ្ញត្តិច្បាប់ទាក់ទិននឹងនគរបាល ដើម្បីបង្កើនការត្រួតពិនិត្យខាងយុត្តាធិការចំពោះសកម្មភាពរបស់នគរបាល នៅថ្នាក់ឃុំ និងថ្នាក់ស្រុក។

ឃ. តម្រូវឱ្យនគរបាលនៅគ្រប់ថ្នាក់ ទាំងថ្នាក់ឃុំ ថ្នាក់ស្រុក ធ្វើសេចក្តីរាយការណ៍រាល់បទល្មើសឱ្យព្រះរាជអាជ្ញាដោយផ្ទាល់ ដើម្បីចាត់វិធានការជាបន្ទាន់ដោយផ្ទាល់លើករណីទាំងនោះ ព្រមទាំងជាប្រយោជន៍ក្នុងការទប់ស្កាត់កុំឱ្យបាត់បង់ប្រយោជន៍ដល់ការស៊ើបអង្កេត និងកុំឱ្យមានការដោះស្រាយខុសច្បាប់។

ង. បង្កើនការត្រួតពិនិត្យរបស់សង្គមលើសកម្មភាពរបស់នគរបាលដើម្បីទប់ស្កាត់អំពើពុករលួយ។

### ២.៣.៣. មេធាវី

ក. ពង្រឹងសេវាជំនួយផ្នែកច្បាប់ ជាពិសេសសម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។ រៀបចំឱ្យមានកញ្ចប់ថវិកាសម្រាប់បង្កើតការិយាល័យជំនួយផ្នែកច្បាប់ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល។ គាំទ្រដល់គម្រោងផ្តល់សេវាច្បាប់សម្រាប់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិចនានា[២៣២]។ បង្កើនតម្លាភាពនៅក្នុងការបញ្ចូលសមាជិកគណៈមេធាវីថ្មីៗ។

ខ. ធានាការបកប្រែភាសាសម្រាប់ជនជាតិដើមភាគតិច នៅក្នុងចំណាត់ការតាមផ្លូវច្បាប់នានា ជាពិសេសនៅក្នុងករណីព្រហ្មទណ្ឌ និងការទាមទារដីធ្លីនានា។

គ. ធានាដល់ការធ្វើកោសល្យវិច្ច័យដោយឥតគិតថ្លៃចំពោះជនរងគ្រោះក្នុងបទល្មើសនានា ដោយមានការសម្របសម្រួលល្អប្រសើរជាមួយមន្ទីរពេទ្យ ឬមានកញ្ចប់ថវិកាពិសេសសម្រាប់បញ្ហានេះ។

## ២.៤. បង្កើនសមត្ថភាព និងផ្តល់អំណាចដល់ប្រជាពលរដ្ឋដើម្បីចូលរួមកែលំអសេវាកម្មយុត្តិធម៌

ក. ផ្តល់អំណាច និងបង្កើនសមត្ថភាពដល់អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច តាមរយៈការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីសិទ្ធិ និងច្បាប់។ ធានាឱ្យមានការចូលរួមពីសំណាក់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិចដើម្បីឱ្យពួកគេអាចលើកឡើងនូវតម្រូវការ ក៏ដូចជាសំណូមពរនានាដោយផ្ទាល់ចំពោះស្ថាប័ន គ្រប់ជាន់ថ្នាក់ក្នុងន័យកែលំអសិទ្ធិទទួលបានយុត្តិធម៌។

ខ. បង្កើតយន្តការមួយដើម្បីធានាដល់តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាយុត្តិធម៌។

គ. លើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងមានសហប្រតិបត្តិការអន្តរស្ថាប័ន ដើម្បីជាប្រយោជន៍ដល់ការកែលំអសិទ្ធិទទួលបានយុត្តិធម៌នៅគ្រប់លំដាប់ថ្នាក់ (មូលដ្ឋាន ស្រុក ខេត្ត និងថ្នាក់ជាតិ)។

ឃ. ពង្រឹងភាពជាអ្នកដឹកនាំក្នុងការកែទម្រង់ប្រព័ន្ធយុត្តិធម៌។ លើកកំពស់ការកសាងសមត្ថភាព និងការអប់រំបណ្តុះបណ្តាលបន្តអំពីច្បាប់ និងសិទ្ធិស្ត្រី ក៏ដូចជាសិទ្ធិរបស់បងប្អូនជនជាតិដើមភាគតិច ដល់អ្នកទាំងឡាយដែលធ្វើការងារពាក់ព័ន្ធក្នុងការផ្តល់សេវាយុត្តិធម៌ដូចជាៈ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី អ្នកបកប្រែច្បាប់សម្រាប់ជនជាតិដើមភាគតិច អ្នកធ្វើកោសល្យវិច្ច័យ និងនគរបាលជាដើម។

---

[២៣២] ក្នុងចំណោមគម្រោងជួចផ្តើមទាំងនេះ ក្រសួងយុត្តិធម៌មានគម្រោងបង្កើតនាយកដ្ឋាន សម្រាប់ជំនួយការផ្នែកច្បាប់សាធារណៈ ដើម្បីបញ្ជូនមេធាវីទៅធ្វើការនៅតំបន់ដាច់ស្រយាល ។

## ៣.៥. បង្កើតឱ្យមានយន្តការដើម្បីសម្របសម្រួលក្នុងការផ្តល់សេវាយុត្តិធម៌

ត្រូវមានចក្ខុវិស័យជាប្រព័ន្ធសម្រាប់រាល់យន្តការ ដែលផ្តល់សេវាកម្មយុត្តិធម៌ទាំងឡាយ ដោយមានការបែងចែកមុខងារទទួលខុសត្រូវក្នុងការដោះស្រាយវិវាទច្បាស់លាស់រវាង (១). ប្រព័ន្ធយុត្តិធម៌ផ្លូវការ (២). យន្តការដោះស្រាយវិវាទក្រៅតុលាការ (៣). យន្តការដោះស្រាយវិវាទក្រៅតុលាការនៅថ្នាក់មូលដ្ឋាន (៤). យុត្តិធម៌មូលដ្ឋាន និង (៥). ច្បាប់របស់ជនជាតិដើមភាគតិច ។

ដើម្បីកែលំអសេវាយុត្តិធម៌ ចាំបាច់ត្រូវតែលើកទឹកចិត្ត និងលើកកម្ពស់ឱ្យមានៈ

ក. ការសម្របសម្រួលអន្តរស្ថាប័ន

ខ. ការចូលរួមរបស់ប្រជាពលរដ្ឋ

គ. សហប្រតិបត្តិការពហុវិស័យ

រាល់ការខិតខំក្នុងការកែលំអ គួរតែត្រូវធ្វើឡើងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ដោយមានការចូលរួម និងប្រកបដោយតម្លាភាព។

ផែនការសាកល្បង គួរតែត្រូវបង្កើតឡើងដើម្បីអនុវត្ត ***ក្រុមពិគ្រោះយោបល់ពហុវិស័យ*** នៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត ដើម្បីបង្កើតយុទ្ធសាស្ត្រនៅមូលដ្ឋាន ទាក់ទងនឹងការកែលំអការផ្តល់សេវាយុត្តិធម៌ ។

*ក្រុមពិគ្រោះយោបល់នេះ* គួរតែធ្វើឡើងដោយមានការចូលរួមពីអន្តរស្ថាប័ន ដែលមានសមាជិកមកពីតុលាការ ស្ថាប័នអយ្យការ ជំនួយផ្នែកច្បាប់ នគរបាល ប្រព័ន្ធពន្ធនាគារ គណៈកម្មការសុរិយោដី អាជ្ញាធរមូលដ្ឋាន (អភិបាលខេត្ត និងអភិបាលស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ) អ្នកតំណាងរបស់ជនជាតិដើមភាគតិច និងអង្គការនៅមូលដ្ឋានផ្សេងៗទៀត (អង្គការក្រៅរដ្ឋាភិបាល អង្គការខាងស្ត្រី សង្គម អង្គការនានា សហជីព វត្តអារាម ។ល។) ។

*ក្រុមពិគ្រោះយោបល់នេះ* គួរត្រូវបានបង្កើតឡើងបន្ទាប់ពីមានសិក្ខាសាលាមួយចំនួន ដោយមានតំណាងចូលរួមពីស្ថាប័នវិស័យផ្សេងៗ ដើម្បីបង្កើនការយល់ដឹងពីសិទ្ធិ និងផ្តល់ព័ត៌មានអំពីដំណើការនៃការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្ន ដើម្បីជាប្រយោជន៍ក្នុងការវិភាគពីតម្រូវការយុត្តិធម៌ ដោយផ្តោតទៅលើ អ្នកក្រីក្រ ស្ត្រី និងជនជាតិដើម ភាគតិច ក៏ដូចជាស្ថានភាពនៃប្រព័ន្ធតុលាការ គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ ព្រមទាំងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ដែលផ្តល់ឱ្យដោយអាជ្ញាធរនៅមូលដ្ឋាន និងយន្តការដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច) ។

*ក្រុមពិគ្រោះយោបល់នេះ* ត្រូវកំណត់យុទ្ធសាស្ត្រថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ដើម្បីជម្រុញសិទ្ធិទទួលបានយុត្តិធម៌ និងបង្កើតផែនការសកម្មភាព ដោយមានតួអង្គពាក់ព័ន្ធទាំងអស់ចូលរួម។ គោលដៅសំខាន់ៗរួមមានៈ (ក). លើកកម្ពស់ការយល់ដឹងពីសិទ្ធិក្នុងចំណោមប្រជាពលរដ្ឋ ជាពិសេសក្រុមគោលដៅដូចជាស្ត្រី អ្នកក្រីក្រ និងជនជាតិដើមភាគតិច (ខ). បង្កើតការត្រួតពិនិត្យ និងវាយតម្លៃ*ប្រព័ន្ធយុត្តិធម៌នៅមូលដ្ឋាន* (គ). លើកទឹកចិត្តឱ្យមានសវនាការជាសាធារណៈរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ (ឃ). អនុវត្តសកម្មភាពជាក់ស្តែងនានា ដើម្បីកែលំអការសម្របសម្រួលអន្តរស្ថាប័ន និងកិច្ចសហការពហុវិស័យនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត (ង). ត្រួតពិនិត្យការកែលំអសេវាយុត្តិធម៌ រួមមានរបាយការណ៍អំពីការអនុវត្តរបស់តុលាការ គណៈកម្មការសុរិយោដី ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ យន្តការយុត្តិធម៌មូលដ្ឋាន និងយន្តការដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិច (ច). លើកកម្ពស់តម្លាភាព និង (ឆ). មានទំនាក់ទំនងល្អរវាងគ្រប់ប្រព័ន្ធ ឬស្ថាប័នទាំងអស់។

*ក្រុមពិគ្រោះយោបល់នេះ* គួរតែបន្តការងារដោយមានការគាំទ្រពីក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងស្ថាប័នជាតិដែលពាក់ព័ន្ធផ្សេងៗទៀត។ ទន្ទឹមនឹងនេះក៏ត្រូវមានក្រុមអ្នកគាំទ្រថវិកា ដែលអាចរាប់បញ្ចូលទាំងក្រសួង-ស្ថាប័នទាំងនោះ អង្គការ UNDP និងទីភ្នាក់ងារអន្តរជាតិផ្សេងៗទៀត។ ក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធផ្សេងៗ គួរតែខិតខំបង្កើតមូលដ្ឋានច្បាប់ ដើម្បីគាំទ្រដល់មុខងាររបស់ក្រុមពិគ្រោះយោបល់នេះ និងផ្សព្វផ្សាយ ឬដោះស្រាយនូវរាល់សំណូមពរទាំងឡាយដែលលើកឡើងដោយពួកគេ។

ក្រុមអ្នកគាំទ្រថវិកា និងសមាជិកនៃក្រុមពិគ្រោះយោបល់ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរស្ថាប័នមួយ ដើម្បីលើកកម្ពស់ការបង្កើតក្រុមពិគ្រោះយោបល់ ដើម្បីសិទ្ធិទទួលបានយុត្តិធម៌នេះ។ ភាគីទាំងអស់ដែលពាក់ព័ន្ធនៅថ្នាក់ខេត្ត និងមូលដ្ឋាន ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងរបស់ខ្លួនផងដែរ ក្នុងការបង្កើតក្រុមពិគ្រោះយោបល់នេះ ធ្វើដូចនេះការងាររបស់ពួកគេត្រូវបានគេតម្រង់ទិសដោយកិច្ចព្រមព្រៀងទាំងនេះ។

តាមរយៈ*ក្រុមពិគ្រោះយោបល់*នេះ គេអាចជួយរួមចំណែកក្នុងការផ្តល់យោបល់ សម្រាប់គោលនយោបាយថ្នាក់ជាតិ ទាក់ទងនឹង:

- ក្របខ័ណ្ឌច្បាប់ សម្រាប់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការទទួលស្គាល់ទូលំទូលាយនៃវិធានទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច និងប្រព័ន្ធដោះស្រាយវិវាទរបស់គេ
- ក្របខ័ណ្ឌច្បាប់សម្រាប់យន្តការដោះស្រាយវិវាទក្រៅតុលាការរបស់សហគមន៍ និងយុត្តិធម៌មូលដ្ឋានដែលមានអំណាចយុត្តាធិការ ( *ក្រុមប្រឹក្សាយុត្តិធម៌* )។
- អនុសាសន៍ផ្សេងៗទៀត ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌។

## ៣. តារាងសង្ខេប ស្តីអំពីកម្មវិធីទទួលបានយុត្តិធម៌ ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច

| | ស្ថានភាព/បញ្ហាចម្បង១ | ទស្សនៈ | យុទ្ធសាស្ត្រ |
|---|---|---|---|
| លក្ខណៈរួម | ជនក្រីក្រ ស្ត្រីនិងជនជាតិដើមភាគតិច ប្រឈមមុខនឹងការលំបាកជាច្រើន ដើម្បីទទួលបាននូវយន្តការមួយដែលត្រឹមត្រូវ មានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវ ដើម្បីដោះស្រាយជម្លោះ ការពារសិទ្ធិរបស់គេ និងត្រួតពិនិត្យការរំលោភអំណាច ។ | ជនក្រីក្រ ស្ត្រីនិងជនជាតិដើមភាគតិច អាចទទួលបាននូវយន្តការមួយដែលត្រឹមត្រូវ មានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវ ដើម្បីដោះស្រាយជម្លោះ ការពារសិទ្ធិរបស់គេ និងត្រួតពិនិត្យការរំលោភអំណាច ។ | ១. ក្របខណ្ឌច្បាប់<br>២. ក្របខណ្ឌ ស្ថាប័ន<br>៣. ការយល់ដឹងពីច្បាប់ និងសិទ្ធិ<br>៤. ការផ្តល់អំណាច |
| តម្រូវការយុត្តិធម៌ | | | |
| ជនក្រីក្រនៅតាមជនបទ | - តម្រូវការយុត្តិធម៌នៅក្នុងសង្គមដោយជនក្រីក្ររួមមាន:<br>១- ទំនាស់ដែលកើតមាននៅនឹងមូលដ្ឋាន<br>២- ទំនាស់ដីធ្លីដែលមានទ្រង់ទ្រាយធំ<br>៣- ការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ<br>៤- ការរំលោភអំណាច (ដូចជាអំពើពុករលួយជាដើម)<br>- ខ្វះការយល់ដឹងពីច្បាប់ និងសិទ្ធិ<br>- ខ្វះការការពារតាមផ្លូវច្បាប់<br>- ខ្វះការចូលរួម | - ជនក្រីក្រអាចទទួលបាននូវយន្តការមួយដែលមានប្រសិទ្ធិភាពត្រឹមត្រូវ និងមានការទទួលខុសត្រូវ ដើម្បី:<br>១. ដោះស្រាយទំនាស់ដែលកើតមាននៅថ្នាក់មូលដ្ឋាន<br>២. ដោះស្រាយទំនាស់ដីធ្លីដែលមានទ្រង់ទ្រាយធំដោយមានការ ការពារសិទ្ធិរបស់គេ<br>៣. មានការការពារ និងមានសំណាងក្នុងករណីដែលគេជាជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ<br>៤. មានការការពារតាមផ្លូវច្បាប់ និងដំណោះស្រាយផ្សេងក្រៅពីជាប់ពន្ធនាគារ បើសិនជាគេជាប់ចោទពីបទព្រហ្មទណ្ឌ<br>៥. បង្ការ និងត្រួតពិនិត្យការរំលោភអំណាច<br>- ជនក្រីក្រមានការយល់ដឹងពីច្បាប់ និងសិទ្ធិ<br>- អង្គការសង្គមផ្នែកសិទ្ធិមនុស្សរឹងមាំ<br>- ជនក្រីក្រចូលរួមនៅក្នុងពហុផ្នែក (វិស័យ) ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌<br>- មានក្របខណ្ឌច្បាប់គ្រប់គ្រាន់ សម្រាប់ដំណោះស្រាយក្រៅពីការដាក់ពន្ធនាគារ ដូចជា ការសម្រុះសម្រួលនៅក្នុងរឿងព្រហ្មទ័ណ្ឌដែលមិនធ្ងន់ធ្ងរ និងគោលការណ៍នៃការផ្តល់ឱកាស ។ | |

| | | | |
|---|---|---|---|
| ស្ត្រី | - ស្ត្រីប្រឈមមុខនឹងការរំលោភបំពានលើផ្នែកយេនឌ័រ:<br>១. អំពើហិង្សាក្នុងគ្រួសារ<br>២. ការរំលោភបំពានផ្លូវភេទ<br>៣. ការផ្តាច់សង្វាស ការលែងលះ (និងការទាមទារអាហារកិច្ចជាដើម)<br>- ស្ត្រីទទួលការរងគ្រោះពីរដងនៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ (ស្ត្រីត្រូវបង់ថ្លៃធ្វើកោសល្យវិច្ច័យ ហើយមិនទទួលសំណងទេ)<br>- ស្ត្រីទទួលបន្ទុកក្នុងការលែងលះ និងការថែទាំកូន ព្រមទាំងបន្ទុកផ្សេងៗទៀតដោយសារការរំលោភអំណាច (ការចំណាយក្រៅច្បាប់)<br>- ខ្វះការយល់ដឹងពីសិទ្ធិស្ត្រីនិងសិទ្ធិកុមារ<br>- ខ្វះការគាំទ្រ នៅពេលរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន<br>- ខ្វះជំនួយផ្នែកផ្លូវច្បាប់ | - ស្ត្រី (និងកូនរបស់គេ) អាចទទួលបាននូវយន្តការដែលមានប្រសិទ្ធិភាពត្រឹមត្រូវ និងមានការទទួលខុសត្រូវដើម្បី:<br>១. មានការការពារប្រឆាំងនឹងអំពើហិង្សា<br>២. មានការការពារប្រឆាំងនឹងការរំលោភបំពានផ្លូវភេទ<br>៣. ដោះស្រាយការផ្តាច់សង្វាស/លែងលះ ដោយមានការការពារសិទ្ធិរបស់គេក៏ដូចជាកូនរបស់គេ<br>- ស្ត្រីមានការយល់ដឹងពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ<br>- ជនរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន មិនត្រូវទទួលរងគ្រោះពីរដងទេ។ គេមិនត្រូវបង់ថ្លៃធ្វើកោសល្យវិច្ច័យ និងត្រូវទទួលសំណងបានគ្រប់គ្រាន់។<br>- ស្ត្រីត្រូវទទួលការគាំទ្រពីផ្នែកច្បាប់ និងសង្គម<br>- អង្គការស្ត្រីត្រូវរឹងមាំ<br>- ស្ត្រីអាចចូលរួមក្នុងការពិភាក្សាពហុវិស័យ<br>- មានក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ<br>- មានក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីដោះស្រាយករណីបោះបង់ចោលគ្រួសារ និងការលែងលះ | |
| ជនជាតិដើមភាគតិច | - ជនជាតិដើមភាគតិចប្រឈមមុខនឹង:<br>១. ទំនាស់កើតឡើងក្នុងសហគមន៍<br>២. ការចូលចាប់យកដីសហគមន៍<br>៣. ការរំលោភសិទ្ធិរបស់គេ នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ ដែលទទួលទោសធ្ងន់ធ្ងរដោយសារតែខ្វះការបកប្រែភាសា និងជំនួយផ្នែកច្បាប់<br>៤. ការរំលោភអំណាច។ រងគ្រោះដោយសារហេតុផលនៃ | - ជនជាតិដើមភាគតិចអាច:<br>១. ប្រើប្រាស់ច្បាប់ទម្លាប់ អាជ្ញាធរ និងយន្តការដោះស្រាយទំនាស់តាមបែបប្រពៃណី (ប្រកបដោយការទទួលខុសត្រូវ និងច្បាស់លាស់)<br>២. មានការការពារសិទ្ធិរបស់ពួកគេប្រឆាំងនឹងការចូលចាប់យកដីសហគមន៍ដោយខុសច្បាប់<br>៣. ដីសហគមន៍ត្រូវបានវាស់វែង និងប្រគល់ប័ណ្ណ<br>៤. គណៈកម្មការសុរិយោដីត្រូវសកម្ម ដោះស្រាយឱ្យទាន់ពេលវេលា ប្រកប | |

| | | | |
|---|---|---|---|
| | ជនជាតិ និងភាសា<br>- ខ្វះការយល់ដឹងពីសិទ្ធិជនជាតិដើមភាគតិច<br>- ខ្វះការរៀបចំ (សហគមន៍)ឱ្យបានត្រឹមត្រូវ<br>- ខ្វះការចូលរួម និងតំណាងនៅក្នុងវិស័យនយោបាយ និងក្នុងរដ្ឋាភិបាល ។<br>- ច្បាប់ភូមិបាលទទួលស្គាល់ដីសហគមន៍ តែដីទាំងនោះមិនបានវាស់វែង និងប្រគល់ប័ណ្ណកម្មសិទ្ធិទេ ។<br>- ច្បាប់ភូមិបាលប្រគល់សិទ្ធិដល់អាជ្ញាធរព្រៃឈើ ដើម្បីគ្រប់គ្រងដីសហគមន៍នៅតាមព្រៃឈើ និងដំណើរការសម្រេចចិត្តរបស់គេ ។ | ដោយតម្លាភាព (ដីគ្មានប័ណ្ណ)<br>៥. ប្រព័ន្ធតុលាការការពារដីរបស់គេ<br>- មានការការពារសិទ្ធិរបស់គេចំពោះមុខសវនាការ និងដំណើរការតាមផ្លូវច្បាប់ (ភាសា និងវប្បធម៌)<br>១. មានការបកប្រែភាសាជនជាតិដើមភាគតិច<br>២. មានសេវាការពារផ្នែកច្បាប់<br>៣. មានការគោរពវប្បធម៌របស់គេនៅក្នុងនីតិវិធីច្បាប់ និងតុលាការ<br>- មានការការពារប្រឆាំងនឹងការរំលោភអំណាច<br>- យល់ដឹងពីសិទ្ធិរបស់គេ<br>- មានការរៀបចំ (សហគមន៍) បានល្អ<br>- ចូលរួម និងសម្របសម្រួលជាមួយវិស័យផ្សេងៗ ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌<br>- មានក្របខណ្ឌគ្រប់គ្រាន់ដើម្បីការពារសិទ្ធិរបស់គេ | |
| ការផ្ដល់សេវាយុត្តិធម៌នៅមូលដ្ឋាន | | | |
| យន្តការដោះស្រាយវិវាទនៅមូលដ្ឋាន (នៅថ្នាក់ភូមិ និង ឃុំ) | ១. អាជ្ញាធរមូលដ្ឋាន មេភូមិ និងក្រុមប្រឹក្សាឃុំ និងនគរបាល ដោះស្រាយទំនាស់នៅមូលដ្ឋានស្ទើរតែទាំងអស់ តាមរយៈការសម្រុះសម្រួល និងយន្តការមិនផ្លូវការផ្សេងទៀត ។ តែវាមិនមានការធានាសមធម៌ ការទទួលខុសត្រូវ និងភាពស្របច្បាប់ទេ ។<br>២. ការសម្រុះសម្រួលនៅមូលដ្ឋាន ហាក់ដូចជាមិនបានជោគជ័យទេ នៅពេលដែលភាគីមិនមានសមភាព និងនៅពេលដែលភាគីណាមួយមិនព្រមបញ្ចប់ | ១. មានប្រព័ន្ធសម្រាប់ដោះស្រាយទំនាស់នៅមូលដ្ឋាន ដែលមានការទទួលស្គាល់ស្របច្បាប់ ក្រោយពីមានការពិគ្រោះយោបល់ ហើយត្រូវបានអនុវត្តយ៉ាងពេញលេញ និងប្រកបដោយការទទួលខុសត្រូវ ។<br>២. អាជ្ញាធរ/អ្នកសម្រុះសម្រួលនៅមូលដ្ឋាន ត្រូវបានបណ្ដុះបណ្ដាលពីការដោះស្រាយទំនាស់ និងសិទ្ធិមនុស្ស (រួមទាំងសិទ្ធិស្ត្រីនិងសិទ្ធិកុមារ) តាមធម្មានុរូប និងមានការទទួលខុសត្រូវ<br>៣. ប្រជាពលរដ្ឋមានការយល់ដឹងពីការដោះស្រាយទំនាស់ក្រៅតុលាការ ហើយនិងសិទ្ធិរបស់គេ ជាពិសេសសិទ្ធិស្ត្រី | |

| | | | |
|---|---|---|---|
| | ៣. មិនមានក្របខណ្ឌគ្រប់គ្រាន់សម្រាប់ការដោះស្រាយទំនាស់នៅមូលដ្ឋាន។ | ៤. ប្រជាពលរដ្ឋបានទទួលព័ត៌មានផ្នែកច្បាប់<br>៥. មានច្បាប់ស្តីពីការដោះស្រាយទំនាស់ក្រៅតុលាការ (ការទទួលស្គាល់ និង ធ្វើនិយ័តកម្មការសម្រុះសម្រួល ផ្សះផ្សា និងអាជ្ញាកណ្តាល) ដែលរួមទាំងការដោះស្រាយទំនាស់នៅមូលដ្ឋានផង។ | |
| ច្បាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច | ១. អាជ្ញាធរប្រពៃណីប្រើយន្តការដោះស្រាយទំនាស់ទៅតាមទំនៀមទម្លាប់របស់គេតែយន្តការនេះមានភាពទន់ខ្សោយ ហើយមិនត្រូវទទួលស្គាល់តាមផ្លូវច្បាប់ដោយអាជ្ញាធរទេ រួមទាំងជនជាតិភាគតិចខ្លួនឯងមួយចំនួនផងដែរ។<br>២. ច្បាប់ភូមិបាលទទួលស្គាល់អាជ្ញាធរប្រពៃណីមួយកម្រិត តែនៅខ្វះការយល់ដឹងផ្នែកច្បាប់ដោយអាជ្ញាធរ ហើយក៏ខ្វះការ យល់ដឹងពីសិទ្ធិរបស់ជនជាតិដើមភាគតិចដែរ។<br>៣. មានសេចក្តីព្រាងគោលនយោបាយមួយ សម្រាប់ជនជាតិដើមភាគតិច កំពុងដាក់ឱ្យមានការពិភាក្សា ដែលបានពិចារណាទៅលើច្បាប់ និងសិទ្ធិដទៃទៀតរបស់ជនជាតិដើមភាគតិច។<br>៤. កម្ពុជាមិនទាន់អនុម័តអនុសញ្ញា ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីជនជាតិដើមភាគតិចនៅឡើយទេ។ | ១. ដំណាក់កាលទី១: មានការអនុវត្តដោយពេញលេញ រាល់ការទទួលស្គាល់ដោយច្បាប់ភូមិបាល ទាក់ទងនឹងដីសហគមន៍ជនជាតិដើមភាគតិច ច្បាប់ប្រពៃណីអាជ្ញាធរប្រពៃណី និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់គេ<br>២. ប្រជាពលរដ្ឋជាតិដើមភាគតិចមានការយល់ដឹង ពីសិទ្ធិមានយន្តការដោះស្រាយទំនាស់របស់គេ យោលទៅតាមច្បាប់ទំនៀមទម្លាប់របស់គេ<br>៣. ច្បាប់ទំនៀមទម្លាប់ជនជាតិដើមភាគតិចកាន់តែរឹងមាំ និងមានចម្នាន់រូប<br>៤. មានយន្តការពិគ្រោះយោបល់ ដោយមានការចូលរួមរបស់ជនជាតិដើមភាគតិចនៅគ្រប់កម្រិត<br>៥. មានក្របខណ្ឌច្បាប់គ្រប់គ្រាន់ (ច្បាប់ជាតិ និងអន្តរជាតិ)<br>៦. ដំណាក់កាលទី២: មានការទទួលស្គាល់ពេញលេញ នូវច្បាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច ប្រកបដោយការទទួលខុសត្រូវ ហើយចែងច្បាស់លាស់ នៅក្នុងប្រព័ន្ធយុត្តិធម៌ថ្នាក់ជាតិ។ | |
| ប្រព័ន្ធយុត្តិធម៌នៅមូលដ្ឋាន | ១. ការសម្រុះសម្រួលនៅមូលដ្ឋាន (ដោយមេភូមិ និងក្រុមប្រឹក្សាឃុំ) មិនអាចធ្វើសេចក្តីសម្រេចបានទេ នៅពេលមានភាគីណាមួយមិនព្រម ក៏ដូចជាការអនុវត្ត | ១. មានស្ថាប័នមួយដែលមានអំណាចយុត្តាធិការនៅថ្នាក់មូលដ្ឋាន (នៅថ្នាក់ស្រុក ឬឃុំ ឬក៏នៅថ្នាក់ស្រុកតែអាចចល័តទៅតាមឃុំ) ត្រូវបានបង្កើតឡើង ក្រោយពីមានដំណើរការពិគ្រោះយោបល់ ដោយមានសមត្ថកិច្ចដោះស្រាយទំនាស់ អនុវត្ត | |

| | | | |
|---|---|---|---|
| ដោយមានអំណាចសម្រេច / អាចជាក្រុមប្រឹក្សាយុត្តិធម៌ នៅថ្នាក់ឃុំ និងស្រុក | កិច្ចព្រមព្រៀងការផ្តល់សិទ្ធិ ព្រមទាំងការចាត់វិធានការប្រឆាំងនឹងការរំលោភជាលក្ខណៈបុគ្គល ឬ ត្រួតពិនិត្យការរំលោភអំណាចដែរ<br>២. អាជ្ញាធរមូលដ្ឋាន និងនគរបាលធ្វើការតាមលក្ខណៈមិនផ្លូវការដោយគ្មានការទទួលខុសត្រូវចំពោះករណីទាំងឡាយដែលតម្រូវឱ្យមានការសម្រេចពីតុលាការ (ការលែងលះ និងបទព្រហ្មទណ្ឌធ្ងន់ធ្ងរ<br>៣. មិនមានអាជ្ញាធរមានយុត្តាធិការនៅថ្នាក់មូលដ្ឋាន (ភូមិ ឃុំ ស្រុក) ដែលមានសមត្ថកិច្ចដោះស្រាយជម្លោះ អនុវត្តសេចក្តីសម្រេច និងផ្តល់សិទ្ធិ<br>៥. វប្បធម៌ផ្នែកច្បាប់ទទួលស្គាល់ការសម្រុះសម្រួល តែវាក៏តម្រូវឱ្យមានការសម្រេចចិត្ត ក្នុងករណីទាំងឡាយដែលការសម្រុះសម្រួលមិនបានជោគជ័យ | កិច្ចព្រមព្រៀង និងផ្តល់សិទ្ធិប្រកបដោយការទទួលខុសត្រូវ។ ស្ថាប័នមានសមត្ថកិច្ចនេះ ត្រូវឆ្លើយតបទៅនឹងតម្រូវការ និងវប្បធម៌នៅមូលដ្ឋាន ដោះស្រាយទំនាស់ដោយសមធម៌ (ដោយមិនរំលោភលើសិទ្ធិបុគ្គល)។ សម្របសម្រួលការសម្រុះសម្រួល តែក៏អាចដោះស្រាយទំនាស់ដែរបើភាគី មិនអាចឈានទៅដល់កិច្ចព្រមព្រៀងណាមួយ មានសមត្ថកិច្ចចេញដីកាបង្ការដើម្បី ការពារសិទ្ធិស្ត្រី និងកុមារ អាចជម្រុញឱ្យមានជាសំណងរដ្ឋប្បវេណីចំពោះ បទល្មើសតូចតាច ដោយប្រើគោល-ការណ៍ផ្តល់ឱកាស ធ្វើឱ្យដំណើរការមានភាពងាយស្រួល និងឆាប់រហ័ស។ ស្ថាប័ននេះត្រូវមានសមាជិកដែលមានធម្មានុភាព សមត្ថភាព និងការទទួលខុសត្រូវ។ វាអាចជាក្រុមប្រឹក្សា ដែលមានសមាជិក៣ នាក់ ហើយដែលហោចណាស់មានម្នាក់ជាស្ត្រី។<br>ដំណាក់កាលទី១: គម្រោងសាកល្បងស្តីពីយុត្តិធម៌មូលដ្ឋានត្រូវបានរៀបចំត្រួតពិនិត្យ និងផ្តល់សុពលភាពដោយមានការចូលរួមពីគ្រប់ផ្នែក។ | |
| ការចែងច្បាស់លាស់ពីសេវាយុត្តិធម៌មូលដ្ឋាន | មិនមានការចែងឱ្យច្បាស់លាស់ពីសេវាយុត្តិធម៌នៅពេលបច្ចុប្បន្ន ដូចជាការដោះស្រាយទំនាស់ក្រៅតុលាការ ទំនៀមទម្លាប់ជនជាតិដើមភាគតិច ប្រព័ន្ធតុលាការដែលមានភាពរលូនជាមួយគ្នាឡើយ<br>១. មិនមានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ និងជាក់លាក់សម្រាប់រាល់សេវាយុត្តិធម៌ទាំងអស់ ដូចជាការសម្រុះសម្រួលនៅថ្នាក់ឃុំ ការដោះស្រាយទំនាស់ក្រៅតុលាការ (គណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ) ច្បាប់ប្រពៃណីរបស់ ជនជាតិដើមភាគតិច និងប្រព័ន្ធតុលាការជាដើម<br>២. ក្នុងការអនុវត្តជាក់ស្តែង មិនមានការសម្របសម្រួលល្អ | មានប្រព័ន្ធសេវាយុត្តិធម៌ថ្នាក់ជាតិមួយ ដែលមានលក្ខណៈច្បាស់លាស់ និងប្រជា-ធិបតេយ្យ<br>១. មានយន្តការនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្តនិងថ្នាក់ជាតិសម្រាប់ការសម្របសម្រួលអន្តរស្ថាប័ន ការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចសហការពហុវិស័យ សម្រាប់ការកែលំអសិទ្ធិទទួលបានយុត្តិធម៌<br>២. មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់សម្រាប់ប្រព័ន្ធនិមួយៗ (ដំណោះស្រាយទំនាស់ក្រៅតុលាការ ប្រព័ន្ធតុលាការ ច្បាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច យុត្តិធម៌នៅតាមមូលដ្ឋាន) ដោយមានចែងច្បាស់លាស់នៅតាមទម្រង់មួយដែលរលូន និងមានលទ្ធផលល្អ<br>៣. មានយន្តការសម្រាប់ការបកស្រាយឱ្យបានច្បាស់លាស់ និងការទទួលខុសត្រូវនៅថ្នាក់ជាតិ ថ្នាក់ខេត្តនិង ថ្នាក់មូលដ្ឋាន | |

| | | | |
|---|---|---|---|
| | ក្នុងចំណោមស្ថាប័នផ្សេងៗគ្នា ដែលផ្តល់សេវាយុត្តិធម៌ នៅថ្នាក់ជាតិ ខេត្ត និងថ្នាក់មូលដ្ឋានទេ ដែលបញ្ហានេះ នាំឱ្យមានការជាន់លើគ្នាមានទំនាស់ និងភាពអសកម្មនៃប្រព័ន្ធ និងសេវាទាំងនេះ ។<br>៣. មិនមានបណ្តាញគ្រប់គ្រាន់ និងជាលក្ខណៈច្បាប់សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការសហការពហុវិស័យ (អង្គការ ម្ចាស់ជំនួយ រដ្ឋាភិបាល អង្គការសង្គមជាដើម) សម្រាប់ការកែទម្រង់ប្រព័ន្ធតុលាការនៅគ្រប់កម្រិត<br>៤. បទពិសោធន៍នៃកិច្ចសហការពហុវិស័យ និងការចូលរួម របស់ប្រជាពលរដ្ឋសម្រាប់គម្រោងសិក្សាស្រាវជ្រាវស្តីពី "សិទ្ធិ ទទួលបានយុត្តិធម៌" ត្រូវបានផ្តល់សុពលភាពទូវរាល់ដំណើរការនៃគម្រោង ហើយអាចនឹងត្រូវបានពង្រីងសម្រាប់ការរៀបចំការប្រតិបត្តិ និងការត្រួតពិនិត្យ នៃកម្មវិធីផ្សេងៗទៀតដែលទាក់ទង នឹងសិទ្ធិទទួលបានយុត្តិធម៌ ។ | ដំណាក់កាលទីមួយ: គម្រោងសាកល្បងនៅតាមបណ្តាខេត្តមួយចំនួន<br><br>ក្រុមពិគ្រោះយោបល់ពហុវិស័យ លើសិទ្ធិទទួលបានយុត្តិធម៌ នៅថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន ដោយមានការចូលរួមរវាងអាជ្ញាធរមូលដ្ឋាន ផ្នែកតុលាការ ដំណោះស្រាយទំនាស់ក្រៅតុលាការ តំណាងជនជាតិដើមភាគតិច តំណាងស្ត្រី អង្គការ និងអ្នកឧបត្ថម្ភនានា (ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងគ្រប់គ្រងដែនដី...<br>កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ? និងអង្គការពលកម្មអន្តរជាតិ? ជាដើម) ក្រុមពិគ្រោះយោបល់នេះរៀបចំយុទ្ធសាស្ត្រថ្នាក់ខេត្ត និងមូលដ្ឋាន ដើម្បីកែលំអ សិទ្ធិទទួលបានយុត្តិធម៌ ដូចជារៀបចំ ត្រួតពិនិត្យវាយតម្លៃ និងផ្តល់សុពលភាព លើការបើកកម្មវិធីគំរូសម្រាប់យុត្តិធម៌នៅថ្នាក់ មូលដ្ឋាន (ក្រុមប្រឹក្សាយុត្តិធម៌ ឬ គំរូផ្សេងទៀត) សម្រួលការសម្របសម្រួលអន្តរស្ថាប័ន ការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចសហការពីគ្រប់ផ្នែក ។ | |
| **គោលនយោបាយថ្នាក់ជាតិ** | ១. ការសម្របសម្រួលអន្តរស្ថាប័ន<br>- ស្ថាប័នថ្នាក់ជាតិ<br>- ក្រុមការងារបច្ចេកទេសផ្នែកកំណែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការ<br>២. ការអភិវឌ្ឍគោលនយោបាយ<br>៣. ការអភិវឌ្ឍផ្នែកច្បាប់<br>៤. ការកសាងសមត្ថភាព និងស្ថាប័ន<br>៥. ដៃគូ<br>៦. ម្ចាស់មូលនិធិ ... | មានប្រព័ន្ធសម្របសម្រួល និងសហការអចិន្ត្រៃយ៍ និងមានសមត្ថភាពមួយរវាងរដ្ឋាភិបាល សង្គមស៊ីវិល អង្គការសហប្រជាជាតិ និងម្ចាស់ជំនួយសម្រាប់កែលំអ សិទ្ធិទទួលបានយុត្តិធម៌<br><br>ស្ថាប័នថ្នាក់ជាតិធានាថែងយ៉ាងច្បាស់លាស់ ឆ្លើយតប និងប្រែក្លាយដំណើរចំរើនទៅមុខ នៅតាមមូលដ្ឋាន ឱ្យទៅជាគោលនយោបាយថ្នាក់ជាតិ ដោយមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ និងមានយន្តការស្ថាប័នប្រកបដោយតម្លាភាព ។ | |

៤. តារាងសង្ខេបស្តីអំពីឧបសគ្គ និងការផ្តល់សេវាយុត្តិធម៌ សម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច

| អ្នកក្រីក្រ | តម្រូវការយុត្តិធម៌ | ការផ្តល់សេវាយុត្តិធម៌ | ការវាយតម្លៃ | អនុសាសន៍ដោះស្រាយបញ្ហា | អនុសាសន៍ធានាយុត្តិធម៌ |
|---|---|---|---|---|---|
|  | បញ្ហានៅមូលដ្ឋាន :<br>-ញឹកញាប់ រយៈពេលខ្លី និងមធ្យម<br>-បញ្ហាប្លែកៗពីគ្នា<br>-ក្នុងចំណោមអ្នកភូមិ<br>-មានតម្លៃ តិចតួច | អាជ្ញាធរមូលដ្ឋាន<br>ប្រធានភូមិ<br>ក្រុមប្រឹក្សាឃុំ<br>អភិបាលស្រុក | វិវាទភាគច្រើនត្រូវបានដោះស្រាយនៅមូលដ្ឋានដោយការសម្រុះសម្រួល<br>ខ្វះសមត្ថភាពខាងច្បាប់ គណនេយ្យភាព និងការអនុវត្តដំណោះស្រាយ | -ប័ណ្ណកម្មសិទ្ធិដីធ្លី<br>-កាត់បន្ថយភាពក្រីក្រ<br>-បង្កើនការយល់ដឹងពីសិទ្ធិ<br>-ដោះស្រាយវិវាទដោយសន្តិវិធី | -កែលំអ ADR<br>-បង្កើតយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន មានសមត្ថភាព ស្របច្បាប់ដោះស្រាយវិវាទដោយ យុត្តិធម៌ និងមានគណនេយ្យភាព |
| -ប្រជាជន ៨៥% រស់នៅតំបន់ជនបទដាច់ស្រយាល<br>-ខ្វះខាតនូវតម្រូវការជាមូលដ្ឋាន<br>-ចំណូលប្រចាំថ្ងៃតិចជាង១ដុល្លារ<br>-ខ្វះខាតក្នុងការទទួលបានសេវាសាធារណៈ ដូចជាខាងសុខភាព អប់រំ និងយុត្តិធម៌ជាដើម<br>-អត្រាភាពមិនចេះអក្សរខ្ពស់<br>-ខ្វះច្បាប់ធានាដល់កម្មសិទ្ធិដីធ្លី<br>-ខ្វះការទទួលបាននូវធនធានហិរញ្ញវត្ថុ | វិវាទដីធ្លីធំៗ :<br>-រីកដាល និងរយៈពេលវែង<br>-សម្បទាន បង្ខំអោយចាកចេញ និងចាប់យកដីធ្លីប្រជាពលរដ្ឋ<br>-អតុល្យភាពរវាងគូភាគី : អ្នកភូមិជាមួយអ្នកមានអំណាច<br>-វិវាទមានតម្លៃខ្ពស់ | គណៈកម្មការសុរិយោដី<br>-តុលាការ<br>-អាជ្ញាធរខាងនយោបាយ | វិវាទភាគច្រើនត្រូវបានដោះស្រាយ<br>គណៈកម្មការសុរិយោដីមិនអាចដោះស្រាយបានបើភាគីម្ខាងមានអំណាច | -ច្បាប់ធានាដល់សុវត្ថិភាពកម្មសិទ្ធិដីធ្លី : កំណត់ព្រំដីចុះបញ្ជីដីធ្លី<br>-មានគោលនយោបាយ ដ៏ត្រឹមត្រូវនិងមានតម្លាភាពស្តីពីការធ្វើសម្បទាន<br>-សម្បទានមានតម្លាភាព<br>-អភិវឌ្ឍន៍ជនបទអ្នកក្រីក្រ (រៀបចំផែនការ និងគាំទ្រ) | កែលំអយន្តការដោះស្រាយវិវាទដីធ្លី ពេលគូភាគីម្ខាងមានអំណាច និងមានសមត្ថភាពក្នុងការសម្រេចលើរឿងក្តី |
| | រឿងក្តីព្រហ្មទណ្ឌ :<br>-ដោយអន្ទើ<br>-ក្រុមបងធំ ប្អូន និងបង្ករបួសស្នាម .. ។ល<br>-បង្កអសន្តិសុខសង្គម<br>-ពុករលួយក្នុងការផ្តល់សេវាសាធារណៈ | -នគរបាល<br>-អាជ្ញាធរមូលដ្ឋាន<br>-តុលាការ | -សម្រុះសម្រួលនៅមូលដ្ឋានជាមួយនគរបាល<br>-ករណីផ្សេងទៀត មិនត្រូវបានដោះស្រាយទេ<br>-ការសម្រុះសម្រួលបង់សំណងដោយនគរបាល ពុំមានសមត្ថភាពស្របច្បាប់ និងខ្វះគណនេយ្យភាព | -កាត់បន្ថយភាពក្រីក្រ<br>-ផ្តល់ឱកាសឱ្យយុវជនក្នុងសង្គម<br>-ទប់ស្កាត់បទល្មើស<br>-ចៀសវាងអំពើពុករលួយ | -បទល្មើសតូចតាចគួរសម្រុះសម្រួលតាមប្រព័ន្ធយុត្តិធម៌មូលដ្ឋាន<br>-យកចិត្តទុកដាក់ដល់ជនរងគ្រោះ: គោលនយោបាយកំណត់តម្លៃ /វិធានការសម្រាប់សំណងជួសជុល<br>-ផ្តល់ឱកាសជជែកការពារ និងបញ្ជូនវិវាទជំនួសឱ្យពន្ធនាគារ ។<br>-សិទ្ធិខាងផ្លូវតុលាការ<br>-ប្រព័ន្ធស៊ើបអង្កេតជនអនីតិជន<br>-គណនេយ្យភាព សេវាសាធារណៈ |

| ស្ត្រី | តម្រូវការយុត្តិធម៌ | ការផ្តល់សេវាយុត្តិធម៌ | ការវាយតម្លៃ | អនុសាសន៍ដោះស្រាយបញ្ហា | អនុសាសន៍ធានាយុត្តិធម៌ |
|---|---|---|---|---|---|



-៥២ %នៃប្រជាជនទាំងអស់
-ស្ត្រីច្រើនជាមេគ្រួសារតែឯង
-៦៥%កំលាំងពលកម្ម ក្នុងវិស័យកសិកម្មជាស្ត្រី
-អត្រាមិនចេះអក្សរច្រើន ជាងបុរស (៤០% /២០%)
-ចំណូលតិចជាងបុរស សំរាប់ការងារដូចគ្នា
-មានតំណែងក្នុងចំណោម អំណាចសេដ្ឋកិច្ច និង នយោបាយតិចជាងបុរស
-ជាជនរងគ្រោះនៃអំពើហិង្សា
-ទទួលបន្ទុកក្នុងការលែងលះ

**តម្រូវការយុត្តិធម៌ ១**

**អំពើហិង្សាក្នុងគ្រួសារ**
-ញឹកញាប់ រីករាល ដាលនិងជាប្រព័ន្ធ
-ជនរងគ្រោះជាស្ត្រី និង ជាកុមារ
-អ្នកប្រព្រឹត្តជាបុរស

**ការផ្តល់សេវាយុត្តិធម៌ ១**

-**អាជ្ញាធរមូលដ្ឋាន**
-**នគរបាល**
- NGO
-តុលាការ (ករណីមានរបួស ស្នាមរូបកាយ)

**ការវាយតម្លៃ ១**

-**វិវាទភាគច្រើនសម្រុះ សម្រួលនៅមូលដ្ឋាន**
-មិនត្រូវបានដោះស្រាយ

ខ្វះច្បាប់ និងខ្វះដំណោះ ស្រាយប្រសិទ្ធិភាព និងយុត្តិធម៌ជូនស្ត្រី

**អនុសាសន៍ដោះស្រាយបញ្ហា ១**

-បណ្តុះបណ្តាលពីការដោះ ស្រាយដោយសន្តិភាព
-ប្រឹក្សាយោបល់

**អនុសាសន៍ធានាយុត្តិធម៌ ១**

-អនុម័តច្បាប់ស្តីពីអំពើហិង្សា ក្នុងគ្រួសារ
-បង្កើតយន្តការដោះស្រាយ វិវាទនៅមូលដ្ឋាន (សមធម៌ និង គណនេយ្យភាព) មាន សមត្ថភាព និងអាចទប់ស្កាត់ កុំឱ្យកើតទៀត

**តម្រូវការយុត្តិធម៌ ២**

**រំលោភសេពសន្ថវៈ និង ផ្លូវភេទផ្សេងទៀត**
-កើតមានគួរកត់សំគាល់
-ជនរងគ្រោះជាស្ត្រី និង ជាកុមារ
-ប្រព្រឹត្តិដោយអ្នកស្គាល់ ជនរងគ្រោះ (បងប្អូន ឬអ្នកជិតខាង)

**ការផ្តល់សេវាយុត្តិធម៌ ២**

-**នគរបាល**
-**អាជ្ញាធរ មូលដ្ឋាន**
- NGO
-តុលាការ ករណីខ្លះ

**ការវាយតម្លៃ ២**

-**នៅមូលដ្ឋានគូភាគីសម្រុះ សម្រួលក្រៅផ្លូវការ**
-**តែតុលាការពិចារណាជនរង គ្រោះរងគ្រោះឱ្យហើយ ពុំមានដំណោះស្រាយ**

-តម្លៃកោសល្យវិច័យ/ប្រាក់ប្រដាប់ក្តី ជាឧបសគ្គក្នុងការមករកតុលាការ
-គ្មានប្រសិទ្ធិភាពសំលេងជូនសជុល

**អនុសាសន៍ដោះស្រាយបញ្ហា ២**

-លុបបំបាត់អំពើហិង្សា ប្រឆាំងស្ត្រី
-លើកតម្កើងស្ត្រី (អប់រំ រកប្រាក់ចំណូល ។ល។)
-ផ្សព្វផ្សាយការយល់ ដឹងសិទ្ធិនារី និងកុមារ ជូន ទាំងអស់គ្នារួម ទាំងបុរស
-មានវិធានការប្រឆាំង អំពើហិង្សាក្នុងគ្រួសារ
-យុទ្ធនាការសាធារណៈ ប្រឆាំងនិងអំពើហិង្សា និងរំលោភបំពានផ្លូវភេទ
-ការពារដល់ក្រុមស្ត្រី ការងារអូន និងស្ត្រីលក់ ស្រាសៀវក្នុងបំពេញការងារ

**អនុសាសន៍ធានាយុត្តិធម៌ ២**

-ធានាថ្លៃកោសល្យវិច្ឆ័យ ដោយឥតគិតថ្លៃ ការពារ សិទ្ធិជនរងគ្រោះនិងសំណង
-ច្បាប់ការពារស្ត្រីដែលងាយ រងគ្រោះ
-ចាត់វិធានការធានាការពារ ការរំលោភបំពានហិង្សា

**តម្រូវការយុត្តិធម៌ ៣**

**លែងលះ/បោះបង់ចោល**
-ភាគច្រើនបង្កឡើងដោយ ហិង្សាក្នុងគ្រួសារ ឬខ្វះការ ទទួលខុសត្រូវជាឪពុក
-អាហារកិច្ច ការគ្រប់គ្រង កូន និងសម្បត្តិរួម

**ការផ្តល់សេវាយុត្តិធម៌ ៣**

-អាជ្ញាធរមូលដ្ឋាន (ប្រមាណជាង ៣០%)
-តុលាការប្រមាណ ៤០%នៃរឿងក្តី ទាំងអស់ (៨០%ប្តឹង ដោយស្ត្រី)

**ការវាយតម្លៃ ៣**

-**សម្រុះសម្រួលដោយ អាជ្ញាធរមូលដ្ឋាន**
-**តុលាការ:** ស្របច្បាប់ តែ តម្លៃខ្ពស់និងខ្វះប្រសិទ្ធភាព

-**ស្រុះស្រួលគ្នានៅមូលដ្ឋាន:** ខ្វះការ ទទួលស្គាល់ពីច្បាប់ ខ្វះគណនេយ្យ-ភាព និងខ្វះការការពារសិទ្ធិ
-**តុលាការ:** ស្ត្រីជាអ្នកទទួលបន្ទុក (តម្លៃខ្ពស់ និងប្រើពេលយូរ)

**អនុសាសន៍ដោះស្រាយបញ្ហា ៣**

-ការទទួលខុសត្រូវ របស់ឪពុកម្តាយ
-យល់ដឹងពីសិទ្ធិកុមារ
-កាត់បន្ថយអំពើ ហិង្សាក្នុងគ្រួសារ
-ផ្តល់សេវាសង្គម ផ្សេងៗ

**អនុសាសន៍ធានាយុត្តិធម៌ ៣**

-កោសល្យវិច្ច័យជូនស្ត្រី ដោយ ឥតគិតថ្លៃ
-ផ្តោតលើសិទ្ធិកុមារ និងអាហារកិច្ច
-ផ្ទេរអំណាចជូន ទៅយុត្តិធម៌ មូលដ្ឋាន ដើម្បីធានាថាការ បណ្តុះអាសន្នការពារសិទ្ធិកុមារ និងស្ត្រី និងអនុវត្តសេចក្តី សម្រេចទាក់ទងលែងលះ

## ជនជាតិដើមភាគតិច



- ១% នៃប្រជាជនទាំងអស់ តែមានច្រើនជាង ៦០% នៅក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី
- ពួកគេនិយាយភាសារបស់គេ មានវប្បធម៌ ជំនឿ ការរៀបចំសង្គម វិធានទំនៀមទម្លាប់ អាជ្ញាធរ និងប្រព័ន្ធដោះស្រាយវិវាទខ្លួនគេ
- កង្វះជាអ្នកតំណាងនៅក្នុងរចនាសម្ព័ន្ធអំណាច
- ពិបាកទទួលសេវាសាធារណៈ : សុខភាព អប់រំ យុត្តិធម៌ និងគណៈកម្មការសុរិយោដី នៅខេត្តមួយចំនួន
- កង្វះសុវត្ថិភាពលើអចលនវត្ថុសហគមន៍
- កង្វះការការពារផ្នែកច្បាប់ និងអ្នកបកប្រែនៅក្នុងតុលាការ និងនៅស្ថាប័នសាធារណៈនានា

## តម្រូវការយុត្តិធម៌

**វិវាទនៅក្នុងសហគមន៍ជនជាតិដើមភាគតិច**
- **បញ្ហាផ្សេងៗ ( កសិកម្ម ការចោរ ជម្លោះប្តីប្រពន្ធ វេរីបំរីហារក្បី ជម្លោះអ្នកជិតខាង ការខូចខាត បង្ករបួសស្នាម... ។ល។**
- **វិលោភវិធានសហគមន៍**
- **បញ្ហាថ្មីៗផ្សេងៗទៀត**

**ការចន្ទ្រានយកដីពីអ្នកក្រៅ**
- អ្នកទិញ ( តាមរយៈអ្នកគ្អកដេរនៅមូលដ្ឋាន) ទាញយកអត្ថប្រយោជន៍ពីជនជាតិដើមភាគតិចដែលខ្វះការយល់ដឹងច្បាប់ដោយទិញខុសច្បាប់ ឬចាប់យកដីរបស់ពួកគេ
- ការដកហូតអចលនវត្ថុ បង្កបញ្ហាផ្សេងៗទៀត

**រឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ**
( មនុស្សឃាត បង្ករបួស)
- **វិវាទថ្មីៗ** ( បង្កដោយក្រុមបងធំ ការប្រើប្រាស់សុរា)
- **វិវាទជាមួយអ្នកក្រៅ**

## ការផ្តល់សេវាយុត្តិធម៌

**អាជ្ញាធរជនជាតិដើមភាគតិច**
- ចាស់ទុំ ( បុរស និងស្ត្រី ) ។
- មេកន្រ្តាញរបស់សហគមន៍

- មេភូមិ
- ក្រុមប្រឹក្សាឃុំ រឿងក្តីខ្លះ)

- **គណៈកម្មការសុរិយោដី**
- តុលាការ
- អាជ្ញាធរនយោបាយ
- NGO មួយចំនួន

- ក្នុងសហគមន៍ ( ករណីខ្លះ)
- **នគរបាល**
- តុលាការ

## ការវាយតម្លៃ

**ភាគច្រើន មានការពេញចិត្តដល់ដំណោះស្រាយ** យោងតាមវិធាន និងតម្លៃរបស់គេ

មានបញ្ហាជាច្រើននៅពេលក្រុមប្រឹក្សាឃុំជាអ្នកក្រៅ ឬរឿងក្តីទៅដល់នគរបាល និងតុលាការ

**មិនបានដោះស្រាយ**

- គណៈកម្មការសុរិយោដីមានតិច និងមិនបានដោះស្រាយ រឿងក្តីឱ្យទៅសហគមន៍ជនជាតិដើមភាគតិច

- វិវាទជាមួយអ្នកខាងក្រៅ: ខ្វះដំណោះស្រាយ
- បញ្ហាជនជាតិដើមភាគតិចនៅក្នុងពន្ធនាគារ

- មិនមានមេធាវី ឬអ្នកបកប្រែសម្រាប់ជនជាតិដើមភាគតិចនៅមុខតុលាការ

## អនុសាសន៍ដោះស្រាយបញ្ហា

- ពង្រឹងប្រព័ន្ធដោះស្រាយវិវាទ និងវប្បធម៌ជនជាតិដើមភាគតិច
- ទឹកន្លែងនៃរចនាសម្ព័ន្ធអំណាចជនជាតិដើមភាគតិចជាមួយប្រព័ន្ធជាតិ ( ឧ.មេភូមិ និងក្រុមប្រឹក្សាឃុំ)
- ភាសារបស់ពួកគេ

- **សុវត្ថិភាពផ្លូវច្បាប់លើដីធ្លី :** ការកំណត់ព្រំដី និងចេញប័ណ្ណ
- ត្រួតពិនិត្យអំពើពុករលួយក្នុងការទិញដី និងសម្បទាន
- ពិនិត្យគោលនយោបាយសម្បទានឡើងវិញ
- អភិវឌ្ឍន៍ជនបទដោយមានការចូលរួមសម្រាប់សហគមន៍ជនជាតិដើមភាគតិចដោយការគាំទ្រហិរញ្ញវត្ថុ

- កាត់បន្ថយភាពក្រីក្រ
- បង្កើតឱកាសសម្រាប់យុវជន
- ពង្រឹងវប្បធម៌ តម្លៃ និងអាជ្ញាធរជនជាតិដើមភាគតិច

## អនុសាសន៍ទាក់ទងនឹងយុត្តិធម៌

- ទទួលស្គាល់ពេញលេញដោយច្បាប់ ចំពោះអាជ្ញាធរជនជាតិដើមភាគតិច និងប្រព័ន្ធដោះស្រាយវិវាទរបស់ពួកគេ ដើម្បីគ្រប់គ្រង និងដោះស្រាយវិវាទផ្ទៃក្នុង និងរវាងក្នុងចំណោមជនជាតិដើមភាគតិច

- បង្កើតផ្លូវច្បាប់ក្នុងការការពារដីជនជាតិដើមភាគតិច ប្រឆាំងនឹងការចន្ទ្រានយកពីអ្នកខាងក្រៅ
- ត្រួតពិនិត្យអំពើពុករលួយក្នុងការចន្ទ្រានយកដីពីអ្នកខាងក្រៅ

- អាជ្ញាធរជនជាតិដើមភាគតិច គួរតែមានសមត្ថកិច្ចក្នុងការដោះស្រាយបទល្មើសនៅមូលដ្ឋាន រួមទាំងក្រុមបងធំដោយមានគាំទ្រពីអាជ្ញាធរខាងក្រៅ
- ការការពារផ្លូវច្បាប់ និងអ្នកបកប្រែសម្រាប់អ្នកជាប់ចោទជាជនជាតិដើម
- រកវិធានការជំនួសអោយពន្ធនាគារ